# រៀបរស់នៅ បែបថ្មី



ការយល់ដឹងថា តើទទួលព្រះគ្រិស្តមានអត្ថន័យដូចម្ដេច

## ចយស៍ ម៉ៃយ័រ

អ្នកនិពន្ធដែលលក់ដាច់បំផុតនៅញូវយ៉កថៃម

# របៀបរស់នៅ

# បែបថ្មី

# របៀបរស់នៅបែបថ្មី

## ការយល់ដឹងអំពីការទទួលព្រះគ្រិស្ត

**និពន្ធដោយៈ**

**អ្នកស្រី ចយស៍ ម៉ៃយ័រ**

Joyce Meyer

**បកប្រែនិងកែសម្រួលដោយៈ**

**លោក ផុន ភារះ**

**អ្នកស្រី ផុន សិរីរតន៍**

**វេជ្ជ.យ៉ែម ទេវីនាថ**

ប្រអប់សំបុត្រលេខ ៥៤៨, ភ្នំពេញ

ព្រះបន្ទូលនៅក្នុងសៀវភៅនេះត្រូវបានដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ
និង ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន។

រក្សាសិទ្ធិគ្រប់យ៉ាង © 2007 ដោយ ព័ន្ធកិច្ច ចយស៏ ម៉ៃយ័រ

អ្នកនិពន្ធសូមទទួលស្គាល់ថា រឿងនិទានដែលលើកយកមកនិយាយនៅក្នុង ជំពូក៣,
នៅទំព័រ១១-១៣ ដកស្រង់ចេញពីប្រភពដើមរបស់ Dr. Monroe Parker និង
ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយ Gospel Projects Press, P.O. Box 643,
Milton, FL 32572; copyright 1977. www.childrensbibleclub.com

របៀបរស់នៅបែបថ្មី

**A New Way of Living**

Printed in Cambodia

# មាតិកា

| | | |
|---|---|---|
| ១. | ការសំរេចចិត្តដ៏សំខាន់ដែលអ្នកមិនធ្លាប់ធ្វើ | ១ |
| ២. | យើងរាល់គ្នាមានបាប | ៥ |
| ៣. | នេះជាពេលសំរាប់ការចុះចូល | ១១ |
| ៤. | របៀបរស់នៅបែបថ្មី | ១៦ |
| ៥. | របៀបគិតបែបថ្មី | ២៥ |
| ៦. | របៀបនិយាយបែបថ្មី | ៣២ |
| ៧. | របៀបនៃការមើលមកកាន់ខ្លួនឯងបែបថ្មី | ៣៧ |
| ៨. | ការផ្លាស់ប្តូរពីភាពភ័យខ្លាចមកកាន់សេចក្តីជំនឿ | ៤៣ |
| ៩. | ជីវិតរីករាយ | ៤៧ |
| | សេចក្តីអធិស្ឋានសំរាប់ការសង្គ្រោះ | ៥១ |
| | ប្រភពនៃអនុសាសន៏ | ៥៣ |

# ជំពូក ១

# ការសំរេចចិត្តដ៏សំខាន់ដែលអ្នកមិនធ្លាប់ធ្វើ

តើអ្នកមិនស្កប់នឹងជីវិតរបស់អ្នក? បើមិនស្កប់ទេ អ្នកក៏មិននៅតែម្នាក់ឯងដែរ។ មានមនុស្សជាច្រើនដែលខ្សោយ អស់កម្លាំង ហើយមិនបានបំពេញនូវគោលបំណងរបស់ខ្លួន។ អ្នកខ្លះបានព្យាយាមរកសាសនាក្នុងក្តីសង្ឃឹមដើម្បីស្វែងរកដំណោះស្រាយទៅតាមការយល់ឃើញរបស់ខ្លួន, ជាហេតុដែលគ្រាន់តែធ្វើឱ្យកាន់តែមានបន្ទុកជាមួយនឹងជីវិតដែលគ្មានន័យ ហើយក៏ជាមធ្យោបាយដែលគ្មានហេតុផលដែលគេត្រូវធ្វើដែរ។ ប្រសិនបើអ្នកបានសាកល្បងទទួលសាសនាណាមួយ នោះមិនមែនមានន័យថាអ្នកបានសាកល្បងទទួលព្រះជាម្ចាស់ជាដំណោះស្រាយ ទៅនឹងជីវិតដែលគ្មានន័យ ធ្លាក់ទឹកចិត្ត ជីវិតដែលស៊ាំថ្នឹកនឹងកំហុសនោះឡើយ។

ប្រសិនបើអ្នកត្រូវការសេចក្តីស្រឡាញ់ ប្រសិនបើអ្នកត្រូវការមិត្តសំឡាញ់ ប្រសិនបើអ្នកត្រូវការការអត់ទោសឱ្យរួចផុតពីអំពើបាប និងប្រសិនបើអ្នកត្រូវការអនាគត... ព្រះយេស៊ូគ្រិស្តគឺជាចម្លើយរបស់អ្នកតែមួយគត់។ ព្រះអង្គកំពុងរងចាំដើម្បីឱ្យជីវិតថ្មីដល់អ្នក ហើយនិងធ្វើឱ្យអ្នកក្លាយជាមនុស្សថ្មីឡើង។

ប្រសិនបើអ្នកមិនស្កប់និងជីវិតរបស់អ្នកទេ អ្នកត្រូវតែផ្លាស់ប្តូរអ្វីមួយ។ ប្រសិនបើយើងនៅតែធ្វើអ្វីៗដូចដែលបានធ្វើពីមុនៗយើងនៅតែមានជីវិតរស់នៅដូចមុនដដែល។ អ្នកត្រូវតែធ្វើការសំរេចចិត្ត នេះហើយជាការសំរេចចិត្តដ៏សំខាន់ដែលអ្នកមិនធ្លាប់ធ្វើ។

ការជ្រើសរើសនេះមានសារៈសំខាន់ជាងការជ្រើសរើសមហាវិទ្យាល័យ ដែលអ្នកត្រូវចូលរៀន អ្នកណាដែលអ្នកនឹងរៀបការជាមួយ តើអ្នកនឹងត្រូវវិនិយោគប្រាក់របស់អ្នកយ៉ាងដូចម្តេច ឬក៏កន្លែងណាដែលអ្នកនឹងរស់នៅ។ ការសំរេចចិត្តនេះវាទាក់ទងទៅនឹងភាពអស់កល្ប៉។ ភាពអស់កល្ប៉គឺជាពេលវេលាដែលគ្មានទីបញ្ចប់ ហើយ

## របៀបរស់នៅបែបថ្មី

យើងគ្រប់គ្នាត្រូវដឹងថាកន្លែងណាដែលយើងត្រូវទៅ។ មានជីវិត បន្ទាប់ពីសេចក្ដីស្លាប់កន្លងផុតទៅ។ នៅពេលដែលអ្នកស្លាប់ មិនមែនមានន័យថា អ្នកបញ្ឈប់ឱ្យមានរូបអ្នកនោះទេគឺអ្នកគ្រាន់តែចាប់ផ្ដើមទៅនៅកន្លែងមួយផ្សេងទៀតប៉ុណ្ណោះ។ ដូចមានពាក្យបានថ្លែងថា ការស្លាប់គឺជាការវិលជុំ។ អ្នកគ្រាន់តែចាកចេញពីកន្លែងមួយ ហើយទៅនៅកន្លែងមួយផ្សេងទៀត។

តើអ្នកចង់មានទំនាក់ទំនងជាមួយព្រះជាម្ចាស់នៅលើផែនដីនេះ ហើយរស់នៅជាមួយព្រះអង្គរហូតអស់កល្បឬទេ? ប្រសិនបើចង់ អ្នកត្រូវទទួលព្រះយេស៊ូគ្រិស្ដជាព្រះអង្គសង្គ្រោះរបស់អ្នក។យើងទាំងអស់គ្នាសុទ្ធតែមានបាប បានប្រព្រឹត្តអំពើបាប ហើយយើងរាល់គ្នាត្រូវការអ្នកសង្គ្រោះយើង។ ព្រះជាម្ចាស់ទ្រង់បានចាត់ព្រះបុត្រាតែមួយរបស់ព្រះអង្គមកដើម្បីសងទៅនឹងទោសនៃអំពើបាបរបស់យើង។ ព្រះអង្គត្រូវបានគេឆ្កាង ហើយទ្រង់ត្រូវបង្ហូរព្រះលោហិតដែលឥតទោសកំហុសរបស់ទ្រង់តបស្នងទៅនឹងការធ្វើខុសរបស់យើងរាល់គ្នា។ ព្រះអង្គបានសោយទិវង្គត់ និងត្រូវបានបញ្ចុះទៅក្នុងផ្នូរ តែនៅថ្ងៃទីបី ព្រះអង្គទ្រង់បានមានព្រះជន្មរស់ពីសេចក្ដីស្លាប់ឡើងវិញ ហើយរហូតមកដល់ពេលនេះ ព្រះអង្គគង់នៅស្ថានសួគ៌ នៅខាងស្ដាំព្រះហស្ដនៃព្រះវរបិតា ជាព្រះអម្ចាស់។ ព្រះអង្គទ្រង់ជាទីសង្ឃឹមនៃភាពសុខសាន្ដ ភាពរីករាយ តែមួយគត់ និងសិទ្ធិដែលនៅជាមួយនឹងព្រះជាម្ចាស់។

ដោយសារតែដូច្នេះហើយ ដើម្បីឱ្យបានរួចពីបាបរបស់យើងម្នាក់ៗ គម្ពីរបង្រៀនថា យើងត្រូវតែសារភាពបាប និង ទទួលស្គាល់ថា ព្រះយេស៊ូគឺជាព្រះអម្ចាស់ ហើយយើងត្រូវតែជឿនៅក្នុងដួងចិត្តរបស់យើងថា ព្រះជាម្ចាស់បានប្រោសព្រះអង្គពីសេចក្ដីស្លាប់ឡើងវិញ។

*ប្រសិនបើមាត់អ្នកប្រកាសថា ព្រះយេស៊ូពិតជាព្រះអម្ចាស់ ហើយបើចិត្តអ្នកជឿថាព្រះជាម្ចាស់ពិត ជាបានប្រោសព្រះយេស៊ូឱ្យមានព្រះជន្មរស់ឡើងវិញមែន នោះអ្នកនឹងទទួលការសង្គ្រោះជាមិនខាន។ រ៉ូម ១០:៩*

# ការសំរេចចិត្តដ៏សំខាន់ដែលអ្នកមិនធ្លាប់ធ្វើ

ការជឿជាក់បែបនេះគឺលើសពីការយល់ដោយចំណេះដឹងធម្មតា ជាភាពស្មោះត្រង់ និងចេញពីដួងចិត្តរបស់យើង ។ មានមនុស្សជាច្រើនជឿថា ពិតជាមានព្រះជាម្ចាស់មែន ក៏ប៉ុន្តែ ពួកគេពុំបានធ្វើឱ្យការរស់នៅរបស់គេស្របតាមព្រះហឫទ័យរបស់ទ្រង់ឡើយ ។ ព្រះជាម្ចាស់គឺជាម្ចាស់ជីវិត ហើយព្រះអង្គសព្វព្រះហឫទ័យឱ្យជីវិតរបស់អ្នកងាកទៅរកព្រះអង្គវិញដោយស្ម័គ្រពីចិត្ត និង ដោយអំណរ ។ ព្រះជាម្ចាស់បានបង្កើតអ្នកមកឱ្យមានសេរីភាព ហើយព្រះអង្គនឹងមិនដែលបង្ខំអ្នកឱ្យជ្រើសរើសយកព្រះអង្គនោះទេ ។ ប៉ុន្តែទោះបីជាអ្នកធ្វើឬមិនធ្វើតាមបំណងព្រះហឫទ័យទ្រង់ក៏ដោយ ក៏វានឹងធ្វើឱ្យមានភាពខុសគ្នាពីគុណភាពនៃជីវិតដែលអ្នករស់នៅលើផែនដីនេះដែរ ហើយវាក៏ជាកត្តាក្នុងការធ្វើការសំរេចមួយ ដែលអ្នកនឹងត្រូវទៅកន្លែងដ៏អស់កល្បជានិច្ចនៅពេលដែលអ្នកស្លាប់ទៅ ។

តើអ្នកបានសំរេចការងារល្អនៅក្នុងជីវិតរបស់អ្នកហើយឬនៅ? ប្រសិនបើនៅទេ ហេតុអ្វីបានជាអ្នកមិនងាកត្រឡប់ទៅរកព្រះអង្គដែលបានបង្កើតអ្នកមកគឺជាអ្នកដែលស្គាល់អ្នកច្បាស់ជាងអ្នកស្គាល់ខ្លួនឯងទៅទៀតនោះ? ប្រសិនបើ ខ្ញុំទិញរថយន្តមួយគ្រឿង ហើយវាចាប់ផ្តើមមានបញ្ហា ខ្ញុំនឹងប្រគល់វាទៅឱ្យអ្នកដែលផលិតវាវិញ រួចគេនឹងជួសជុលវាជាមិនខាន ។គោលការណ៍ដូចនេះក៏ដូចជាមួយព្រះជាម្ចាស់ផងដែរ ។ ព្រះទ្រង់បានបង្កើតអ្នកមក ហើយទ្រង់ក៏ស្រឡាញ់អ្នកខ្លាំងណាស់ ។ ប្រសិនបើអ្នកមិនស្កប់នឹងជីវិតរបស់អ្នកនោះទេ ចូរយកជីវិតនេះទៅឯព្រះអង្គវិញ នោះទ្រង់នឹងកែកុនវា ។

ដូចខ្ញុំបាននិយាយពីមុនរួចមកហើយថា នឹងគ្មានអ្វីផ្លាស់ប្តូរទេ ដរាបណាអ្នកមិនធ្វើការសំរេចចិត្ត ។ តើអ្នកចង់ក្លាយទៅជាគ្រិស្តបរិស័ទដែរឬទេ? តើអ្នករួចរាល់ហើយឬនៅក្នុងការផ្ទេរមិនគ្រាន់តែបាបរបស់អ្នក ទៅព្រះជាម្ចាស់ គឺថែមទាំងជីវិតរបស់អ្នកទៀតផងនោះ? តើអ្នករួចរាល់ហើយឬនៅក្នុងការដើរចេញពីជីវិតចាស់ដែលពោរពេញដោយអំពើបាបរបស់អ្នក ហើយរៀនរស់នៅតាមរបៀបថ្មី ដែលរស់នៅជាមួយព្រះជាម្ចាស់និងសំរាប់ព្រះអង្គ? ប្រសិនបើអ្នកត្រៀមខ្លួនរួចហើយ សូមអានបន្តទៅមុខទៀត

# របៀបរស់នៅបែបថ្មី

ពីព្រោះមានជីវិតមួយកំពុងរងចាំអ្នក ដែលវាលើសពីការស្រមើស្រមៃដ៏វិសេសបំផុតរបស់អ្នកទៅទៀត ។ជីវិតនោះគឺសំរាប់គ្រប់គ្នាទាំងអស់ ។គ្មាននរណាម្នាក់មិនអនុញ្ញាតឱ្យយទទួលយកជីវិតនោះឡើយ ។ នេះគឺជាអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលអំពីអនាគតរបស់អ្នកៈ

*យើងស្គាល់ច្បាស់នូវគំរោងការដែលយើងបានគ្រោងទុកសំរាប់អ្នករាល់គ្នា ជាគំរោងការដែលផ្តល់សេចក្តីសុខសាន្តដល់អ្នករាល់គ្នា គឺមិនមែនឱ្យអ្នករាល់គ្នាត្រូវវេទនាទេ ។ យើងនឹងផ្តល់សេចក្តីសង្ឃឹម និង អនាគតល្អឱ្យអ្នករាល់គ្នា នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ។ (យេរេមា ២៩:១១)*

គ្មាននរណាម្នាក់អាចធ្វើការជ្រើសរើសជំនួសបានអ្នកទេ។ នេះជាកិច្ចការដែលអ្នកត្រូវធ្វើ ហើយមានតែអ្នកប៉ុណ្ណោះដែលត្រូវធ្វើការនេះដោយផ្ទាល់ខ្លួនឯង។ តើជីវិតបែបណាដែលអ្នកប្រាថ្នាចង់បាន? តើអ្នកពិតជាចង់ដើរតាម គំរូដែលអ្នកឃើញនៅក្នុងសង្គមរបស់យើងរស់នៅសព្វថ្ងៃនេះឬ? ព្រះបន្ទូលរបស់ព្រះជាម្ចាស់ថ្លែងថា យើងបានមកក្នុងពិភពលោកនេះដោយខ្លួនទទេហើយយើងនឹងទៅវិញទទេដែរ(១ធីម៉ូថេ៦:៧) ។ ព្រះជាម្ចាស់គឺជា **អាល់ហ្វា** និង **អូម៉េហ្គា** ជាដើមដំបូង និងក៏ជាទីបញ្ចប់ផងដែរ ។ កាលពីដើមដំបូងមានព្រះជាម្ចាស់ជាស្រេច ហើយនៅទីបញ្ចប់ក៏នឹងមានព្រះជាម្ចាស់ដែរ ។ គ្រប់មនុស្សទាំងអស់នឹងមានវត្តមាននៅចំពោះព្រះភ័ក្ត្ររបស់ព្រះអង្គ ហើយនិងត្រូវរៀបរាប់នូវជីវិតរបស់ខ្លួនដល់ទ្រង់(រ៉ូម១៤:១២) ។ ឥឡូវនេះជាពេលដែលអ្នកត្រូវរួចរាល់សំរាប់ការនេះ ។ ខ្ញុំតែងតែនិយាយថា "រួចរាល់ហើយឬនៅ ព្រះយេស៊ូកំពុងតែយាងមកហើយ ។" ចូរត្រៀមខ្លួនឥឡូវនេះចុះ ចូរធ្វើការសំរេចចិត្តដ៏ត្រឹមត្រូវពីព្រោះវាអាចនឹងយឺតនៅពេលក្រោយៗ ។

# ជំពូក ២

# យើងគ្រប់គ្នាមានបាប

បាបគឺជាការប៉ះពាល់ដែលគ្រោងទុកជាមុន ទៅនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ យើងរាល់គ្នាបានប្រព្រឹត្តអំពើបាប។ គ្មាននរណាម្នាក់នៅលើផែនដីនេះមិនដែលប្រព្រឹត្តអំពើបាបនោះឡើយ(រ៉ូម៣:២៣,សាស្តា៧:២០)។ នោះគឺជាដំណឹងអាក្រក់ ប៉ុន្តែក៏មានដំណឹងល្អផងដែរ។ យើងរាល់គ្នាអាចត្រូវបានអត់ទោស ហើយអាចនឹងបានសុចរិតជាមួយនឹងព្រះជាម្ចាស់។

ចាប់តាំងពីពេលដែលមនុស្សបានប្រព្រឹត្តអំពើបាប ហើយបាត់បង់សិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ ដែលព្រះជាម្ចាស់ប្រទានជាអំណោយ និងឱ្យទទួលយក:

*គ្រប់ៗគ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយគ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ តែដោយសារព្រះគុណ និង ដោយសារការប្រោសលោះដែលស្ថិតនៅក្នុងអង្គព្រះគ្រិស្តយេស៊ូ ព្រះអម្ចាស់ប្រោសគេឱ្យបានសុចរិតដោយឥតគិតថ្លៃ។*

*រ៉ូម ៣:២៣-២៤*

ព្រះយេស៊ូបានបង់ថ្លៃលោះអំពើបាបរបស់យើងរួចរាល់ហើយ អ្វីដែលអ្នកត្រូវធ្វើនោះគឺ ជឿលើការនេះ ហើយនិងទទួលយក។ ប្រសិនបើអ្នកយល់ព្រមទទួលថា ខ្លួនមានបាប សោកស្តាយចំពោះការទាំងនោះ ហើយពិតជាចង់ដើរចេញពីអំពើបាបទាំងអស់នោះទាំងស្រុងមែន ព្រះជាម្ចាស់នឹងអត់ទោសឱ្យអ្នក ហើយនឹងធ្វើឱ្យអ្នកទៅជា

មនុស្សមួយថ្មីផ្សេងទៀត ។

*ប៉ុន្តែបើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ដែល មានព្រះហឫទ័យស្មោះស្ម័គ្រនិងសុចរិត ទ្រង់នឹងអត់ទោសយើងឱ្យរួចពីបាប ព្រមទាំងជំរះយើងឱ្យបានបរិសុទ្ធរួចពីគ្រប់អំពើទុច្ចរិតទាំងអស់ផង ។ ( ១យ៉ូហាន១:៩)*

អ្នកមិនត្រូវរង់ចាំឱ្យព្រះជាម្ចាស់ធ្វើអ្វីមួយនោះឡើយ ។ ព្រះទ្រង់បានធ្វើនូវអ្វីដែលចាំបាច់រួចមកហើយ ។ ព្រះទ្រង់បានប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមកដើម្បីសុគតជំនួសយើងរាល់គ្នា ដោយព្រោះតែយញ្ញបូជាដែលឥតខ្ចោះ និងគ្មានបាបដែលអាចថ្វាយលោះទង្វើខុសឆ្គងរបស់យើង ។ មានយុត្តិធម៌គ្រប់គ្រាន់ ហើយយើងមានសេរីភាពដោយការជឿព្រះយេស៊ូគ្រិស្ដ និងចូលមកកាន់ការទំនាក់ទំនងដ៏ជ្រាលជ្រៅជាមួយនឹងព្រះជាម្ចាស់តាមរយៈព្រះអង្គ ។ យើងមិនអាចទៅកាន់ព្រះជាម្ចាស់ដោយខ្លួនឯងបានឡើយ យើងត្រូវការអ្នកជួយជ្រោមជ្រែង ។ យើងត្រូវការនរណាម្នាក់ដូចជាមេអណ្ដើក ហើយអ្នកនោះគឺព្រះយេស៊ូ ។ ព្រះយេស៊ូគង់នៅចន្លោះរវាងយើងនិងព្រះជាម្ចាស់,ជាចន្លោះនៃអំពើបាបរបស់យើងហើយព្រះអង្គនាំយើងទៅកាន់ព្រះជាម្ចាស់ ។

ដូចជាកូនក្មេងដែលមានលក្ខណៈឪពុកនៅក្នុងខ្លួនរបស់គេ( ឈាមរបស់គាត់ DNA របស់គាត់ ក្រូម៉ូស៊ូមរបស់ឪពុកពីក្នុង ។ល ។) ដូច្នេះលក្ខណៈរបស់ព្រះជាម្ចាស់មាននៅក្នុងព្រះគ្រិស្ដ ដែលទ្រង់ធ្វើការផ្សះផ្សារពិភពលោកនេះឱ្យជានានឹងព្រះជាម្ចាស់វិញដោយព្រះអង្គផ្ទាល់ ។ ព្រះជាម្ចាស់ស្រឡាញ់មនុស្សដែលព្រះអង្គបានបង្កើតមក ហើយព្រះអង្គមិនសព្វព្រះហឫទ័យនឹងឃើញគេត្រូវបានលក់ឱ្យធ្វើជាទាសករនៃអំពើបាប ដោយ មិនប្រទានឱ្យមានច្រកចេញពីការទាំងនោះវិញឡើយ ។ ព្រះយេស៊ូគឺជាផ្លូវ!

# យើងគ្រប់គ្នាមានបាប

# អំពើបាបនាំមកនូវបណ្តាសា

ព្រះបន្ទូលរបស់ព្រះជាម្ចាស់ថ្លែងថា អំពើបាបរបស់យើងនឹងតាមរកយើង (ជនគណនា៣២:២៣)។ អំពើបាបនាំមកនូវបណ្តាសា ហើយការគោរពចុះចូលវិញ នាំមកនូវព្រះពរ(ទុតិយកថា២៨)។ វាអាចកើតឡើង នៅពេលណាមួយដែលអ្នកនោះមិនចាប់អារម្មណ៍ជាមួយនឹងបាបរបស់ខ្លួន។ ជីវិតរបស់គេហាក់បីដូចជាល្អដូចគេដូចឯងដែរ ក៏ប៉ុន្តែនៅទីបញ្ចប់វាតែងតែលេចឱ្យឃើញនូវអ្វីដែលគេបានសំរេចចិត្តធ្វើ។

នៅពេលដែលយើងធ្វើការជ្រើសរើសយកជីវិតក្នុងអំពើបាប ជាជាងជីវិតដែលគោរពកោតខ្លាចព្រះជាម្ចាស់ យើងនឹងមានបទពិសោធនៃព្រលឹងដែលវេទនា។មនុស្សមិនគ្រាន់តែប្រសើរជាងរូបកាយដែលធ្វើឡើងដោយសាច់ឈាមនិងឆ្អឹងនោះទេ។មនុស្សក៏មានវិញ្ញាណ និងព្រលឹងដែលរាប់បញ្ចូលទាំងគំនិត បំណង និង អារម្មណ៍ផងដែរ។ នេះជាលក្ខណៈផ្ទាល់ខ្លួនរបស់មនុស្ស។ មនុស្សបាបមានការរងទុក្ខនៅក្នុងគំនិតរបស់គេ។ គេពេញទៅដោយភាពតានតឹង ហើយមិនថាអ្វីដែលគេធ្វើនោះទេ ឬបានកាន់កាប់នោះទេ គឺគ្មានអ្វីមួយដែលធ្វើឱ្យគេបានស្កប់ចិត្តបានឡើយ។ គេក៏រងទុក្ខនៅក្នុងអារម្មណ៍របស់គេផងដែរ។ តាំងពីគេបានធ្វើការជ្រើសរើសផ្លូវជីវិតដោយផ្ទាល់ គេបែរជាធ្លាក់ទឹកចិត្ត ហើយខឹង(អារម្មណ៍ទុក្ខព្រួយ) នៅពេលដែលកិច្ចការណាមួយមិនបានស្របជាមួយនឹងខ្សែជីវិតនោះ។ ពួកគេមិនដឹងអ្វីអំពីសេចក្តីជំនឿនោះឡើយ។ ការទុកចិត្តលើព្រះជាម្ចាស់-មានឥទ្ធិពលជាងខ្លួនគេផ្ទាល់-គឺមិនអាចពន្យល់ពួកគេបាន។ ពួកគេមិនធ្លាប់ឱ្យព្រលឹងរបស់គេសំរាកទេ ពីព្រោះអ្នកដែលអាចចូលទៅកាន់ទីសំរាករបស់ព្រះជាម្ចាស់បាន មានតែតាមរយៈការជឿលើទ្រង់ប៉ុណ្ណោះ (ហេប្រឺ៤:៣)។

ពិតហើយ ជីវិតនៃអំពើបាប ជាជីវិតដែលពេញទៅដោយបណ្តាសា។ គ្មានអ្វីដែល

ល្អចេញមកពីវាបានឡើយ ។ នេះគឺជាអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលអំពីអស់អ្នកដែលខំប្រឹងព្យាយាមរស់នៅដោយមិនចាំបាច់មានព្រះអង្គៈ

*ព្រះអង្គនឹងធ្វើឱ្យមនុស្សលោកវេទនា ពួកគេនឹងដើរដូចមនុស្សខ្វាក់ ដ្បិតពួកគេប្រព្រឹត្តអំពើបាបទាស់នឹងព្រះហឫទ័យរបស់ព្រះអម្ចាស់ ឈាមរបស់ពួកគេនឹងខ្ចាយទៅគ្រប់ទីកន្លែងដូចធូលីដី សាកសពរបស់ពួកគេប្រៀបបាននឹងសំរាម ។ នៅថ្ងៃព្រះអម្ចាស់ខ្ញាល់យ៉ាងខ្លាំង ប្រាក់ ឬ មាសពុំអាចរំដោះពួកគេបានទេ ។ ផែនដីទាំងមូលនឹងត្រូវរលាយដោយសារភ្លើងនៃព្រះពិរោធ ។ ពេលព្រះអង្គលុបបំបាត់មនុស្ស ទាំងអស់ពីផែនដី ជាពេលមួយដ៏គួរឱ្យព្រឺខ្លាចបំផុត ។ ( សេផានា១:១៧-១៨)*

ខគម្ពីរទាំងនេះគឺគួរឱ្យខ្លាច ក៏ប៉ុន្តែពួកគេមិនចាំបាច់តតាំងនឹងភាពភ័យខ្លាចនៅក្នុងចិត្តនៃអ្នកដែលស្មោះត្រង់នឹងព្រះយេស៊ូគ្រិស្តនោះឡើយ ។ អស់អ្នកដែលជឿលើ ព្រះយេស៊ូ នឹងមិនដែលត្រូវជំនុំជំរះ ឬ ទទួលទ័ណ្ឌកម្មនោះឡើយ ។ ( យ៉ូហាន ៣:១៨)

## ភិរុទ្ធភាព និង ការដាក់ទោស

ភិរុទ្ធភាពគឺជាដៃគូដែលមានភាពរឹងមាំនឹងមនុស្សមានបាប ។ មនុស្សម្នាក់អាចនឹងធ្វើកិច្ចការផ្សេងៗខុសគ្នាដើម្បីមិនអើពើនឹងភិរុទ្ធភាពនោះ ក៏ប៉ុន្តែការស្រុតចុះនៅខាងក្នុងគាត់ ធ្វើឱ្យគាត់ដឹងថាខ្លួនធ្វើនេះមិនត្រឹមត្រូវទេ ។ ព្រះយេស៊ូបានមានព្រះបន្ទូលថាមនុស្សបាបមិនអាចរត់គេចពី ភិរុទ្ធភាពរបស់ខ្លួនបានឡើយ ( យ៉ូហាន ៩:៤១) ។

ព្រះគម្ពីរត្រូវបានបែងចែកជា សម្ព័ន្ធមេត្រីចាស់ និង សម្ព័ន្ធមេត្រីថ្មី ។ សម្ព័ន្ធមេត្រីចាស់គឺ"ចាស់" ។ ជាតំណាងឱ្យកិច្ចព្រមព្រៀងដែលចាស់ ជាការមួយដែលព្រះជាម្ចាស់បានធ្វើការគ្របបាំងនូវអំពើបាបរបស់មនុស្ស ទំរាំដល់ពេលដែលព្រះយេស៊ូត្រូវបានយាងមកគឺដើម្បីធ្វើកិច្ចព្រមព្រៀងថ្មីមួយផ្សេងទៀត ។តាមរយៈប្រព័ន្ធនៃការធ្វើយ័ញ្ញ

# យើងគ្រប់គ្នាមានបាប

បូជារំដោះអំពើបាបចាស់ខាងលើនេះ  បាបរបស់មនុស្សអាចគ្រាន់តែគ្របបាំងប៉ុណ្ណោះ ប៉ុន្តែមិនដែលដកចេញនោះទេ។  ភិរុទ្ធភាពគឺនៅតែមានដដែល។  ទោះជាយ៉ាងណាក៏ដោយសម្ព័ន្ធមេត្រីថ្មីដែលនៅក្រោមកិច្ចព្រមព្រៀងថ្មី  យើងមានយ័ញ្ញបូជាដែលល្អឥតខ្ចោះ និងចុងក្រោយបំផុត ដែលមិនមែនគ្របបាំងអំពើបាបនោះទេ តែដកចេញពីយើងវិញ។ យ័ញ្ញបូជានេះមិនគ្រាន់តែលាងបាបចេញប៉ុណ្ណោះទេគឺថែមទាំងសំអាតនូវកំហុសដែលមកជាមួយបាបនោះទៀតផង។

សូមអានខគម្ពីរខាងក្រោមយឺតៗដោយសញ្ជឹងគិតនូវអំណាចដែលមានថ្លែងក្នុងខគម្ពីរទាំងនេះ។ ខម្ពីរទាំងនេះដកស្រង់ចេញពីគម្ពីរហេប្រឺ ជំពូក១០។

*ព្រះយេស៊ូគ្រិស្តថ្វាយព្រះកាយរបស់ព្រះអង្គម្តងជាសូរេច  តាមព្រះហឫទ័យព្រះជាម្ចាស់ ហេតុនេះហើយបានជាព្រះអង្គប្រោសយើងឱ្យបានវិសុទ្ធ។(ហេប្រឺ១០:១០)*

*រីឯព្រះគ្រិស្តវិញ  បន្ទាប់ពីព្រះអង្គបានថ្វាយយញ្ញបូជាតែមួយ  ដើម្បីរំដោះបាបរួចហើយ ព្រះអង្គគង់នៅខាងស្តាំព្រះជាម្ចាស់រហូតតទៅ។(ហេប្រឺ១០:១២)*

*ព្រះអម្ចាស់មានព្រះបន្ទូលថា លុះគ្រានេះកន្លងផុតទៅ យើងនឹងចងសម្ពន្ធមេត្រីជាមួយគេដូចតទៅនេះ:  យើងនឹងដាក់ក្រឹត្យវិន័យទាំងប៉ុន្មានរបស់យើងក្នុងចិត្តរបស់ពួកគេ  យើងនឹងចារក្រឹត្យវិន័យទាំងនោះទុកក្នុងប្រាជ្ញារបស់ពួកគេដែរ។* បន្ទាប់មកព្រះវិញ្ញាណមានព្រះបន្ទូលបន្ថែមទៀតថា: *ហើយយើងក៏មិននឹកនាពី  អំពើបាប  និងអំពើទុច្ចរិតរបស់គេទៀតដែរ។(ហេប្រឺ១០:១៦-១៧)*

*យើងត្រូវនាំគ្នាចូលទៅជិតព្រះអង្គដោយចិត្តទៀងត្រង់  (ស្មោះត្រង់និងការគោរពដ៏ខ្ពស់បំផុត)  ពោរពេញដោយជំនឿមាំមួន(ដោយលំអៀងចេញពីជីវិតចាស់ទាំងស្រុងហៅទោរទន់ទៅកាន់ព្រះជាម្ចាស់ ទាំងជឿជាក់ និង ទុកចិត្តនៅក្នុងអំណាច ព្រះប្រាជ្ញា*

*ញាណ និង ភាពត្រឹមត្រូវរបស់ព្រះអង្គ ) និង មានចិត្តបរិសុទ្ធ ជ្រះស្រឡះពីគំនិតសៅហ្មង ( អំពើអាក្រក់) ព្រមទាំងមានរូបកាយលាងដោយទឹកដ៏បរិសុទ្ធផង ។ ( ហេប្រឺ ១០:២២)*

ខគម្ពីរខាងលើនេះប្រាប់យើងអំពីសារៈសំខាន់យ៉ាងខ្លាំង និង ការល្អជាច្រើន ។ ជាបឋម គឺព្រះយេស៊ូជាយញ្ញបូជាតែម្តងជាសូរេច និង សំរាប់ទាំងអស់គ្នា ហើយមិនចាំបាច់ត្រូវការយញ្ញបូជាណាមកបន្ថែមលើនេះទៀតឡើយ ។ នៅក្រោមកិច្ចព្រមព្រៀងចាស់យញ្ញបូជាចាំបាច់ត្រូវការធ្វើម្តងហើយម្តងទៀត ហើយគេមិនដែលយកនូវកំហុសទាំងនោះចេញបានឡើយ ។ ព្រះយេស៊ូបានក្លាយទៅជាយញ្ញបូជាតែមួយគត់ ដែលល្អគ្រប់ពេលទាំងអស់ ហើយអាចដោះបាប និង ភិរុទ្ធភាពចេញទៀតផង ។

ភិរុទ្ធភាពគឺត្រូវបានដកចេញយ៉ាងពិតប្រាកដ តែគេនៅតែត្រូវការរៀនអំពី របៀបរស់នៅយ៉ាងមានសិរីភាពពីអារម្មណ៍ដែលចេះតែខុសនោះ ។ ជាក់ស្តែងជីវិតថ្មី ដែលរស់នៅសំរាប់ព្រះគ្រិស្ត តម្រូវឱ្យអ្នកនោះរៀនរស់នៅអោយឆ្ងាយពីអារម្មណ៍របស់គេទាំងប៉ុន្មាន ។ ពួកគេមិនត្រូវអនុញ្ញាតឱ្យអារម្មណ៍ធ្វើជាម្ចាស់ត្រួតត្រាលើខ្លួនឯងបានទៀតឡើយ ។ ពួកគេត្រូវតែរៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយចុះចូលនឹងព្រះបន្ទូលនោះ មិនថាពួកគេមានអារម្មណ៍យ៉ាងណានោះឡើយ ។ ការរស់នៅដែលចុះចូលបែបនេះ នាំទៅកាន់ព្រះពរលើសពីអ្វីដែលយើងប្រៀបធៀបទៅទៀត ។

# ជំពូក ៣

## នេះជាពេលសំរាប់ការចុះចូល

អ្នកបានទទួលព្រះគ្រិស្តរួចហើយ ហើយក៏បានសុំសៀវភៅនេះដើម្បីជួយអ្នកក្នុងការចាប់ផ្តើមជីវិតថ្មីជាមួយនឹងព្រះគ្រិស្ត ឬមួយក៏អ្នកទទួលបានសៀវភៅនេះ ហើយយើងសង្ឃឹមថា អ្នករួចរាល់ក្នុងការធ្វើការសំរេចចិត្តនៅពេលនេះ ។

ព្រះគម្ពីរយ៉ូហាន៣:១៦ថ្លែងថា:" *ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីឱ្យអស់អ្នកដែលជឿលើព្រះបុត្រាមានជីវិតអស់កល្បជានិច្ច គឺមិនឱ្យគេវិនាសឡើយ* " ។

ខ្ញុំសូមចែកចាយរឿងមួយដែលនឹងជួយអ្នកឱ្យយល់អំពីអំណាចគម្ពីរខាងលើនេះ ។

នៅរដូវត្រជាក់ក្នុងទីក្រុងឈីកាហ្គូនាពេលយប់ងងឹត មានព្យុះទឹកកកមួយកើតឡើង ។ មានក្មេងប្រុសម្នាក់កំពុងលក់កាសែតនៅជ្រុងផ្លូវមួយ ។ មនុស្សម្នានាំគ្នាជ្រកឱ្យផុតពីអាកាសធាតុត្រជាក់នោះឯក្មេងប្រុសនោះវិញដោយព្រោះត្រជាក់ខ្លាំងពេកពិតជាមិនបានព្យាយាមលក់កាសែតឱ្យបានច្រើននោះទេ ។ ក្មេងនោះបានដើរតម្រង់ទៅរកលោកប៉ូលីសម្នាក់ហើយនិយាយថា"លោក, តើលោកមានដឹងរឿងអ្វីកើតឡើងឬទេ? តើក្មេងប្រុសក្រីក្រអាចរកកន្លែងកក់ក្តៅកេងពេលយប់នៅឯណា? លោកឃើញទេ ខ្ញុំគេងនៅក្នុងប្រអប់ក្រដាសមួយ នៅជិតកាច់ជ្រុងនោះ ហើយនិងក្នុងផ្លូវឌឹងហែម ជួននឹងអាកាសធាតុត្រជាក់ដ៏អាក្រក់បែបនេះ ។ វាពិតជាការប្រពៃណាស់ ប្រសិនបើមានកន្លែងដែលកក់ក្តៅសំរាប់នៅ ។"

លោកប៉ូលីសបានសម្លឹងមើលក្មេងប្រុសតូចនោះ ហើយនិយាយថា"ល្អណាស់ ពូនឹងប្រាប់ក្មួយថាត្រូវធ្វើយ៉ាងណា, ក្មួយចុះតាមផ្លូវទៅនឹងឃើញផ្ទះសធំមួយ ហើយចូរក្មួយគោះទ្វារផ្ទះនោះទៅ ។ នៅពេលមានអ្នកចេញមកក្រៅ ក្មួយគ្រាន់តែនិយាយ ព្រះគម្ពីរយ៉ូហាន៣:១៦ នោះគេនឹងអនុញ្ញាតឱ្យក្មួយចូលក្នុងជាមិនខាន ។"

## របៀបរស់នៅបែបថ្មី

ដូច្នេះក្មេងប្រុសនោះក៏បានធ្វើតាម ក្មេងនោះដើរឡើងតាមជណ្តើរ តម្រង់ទៅកាន់ទ្វារ ហើយបានគោះទ្វារនោះ រួចមកស្ត្រីម្នាក់បានឆ្លើយតបមកវិញ។ ក្មេងនោះបានមើលទៅស្ត្រីនោះ ហើយនិយាយអំពី "យ៉ូហាន ៣:១៦"។

ស្ត្រីបាននិយាយថា "សូមចូលមកខាងក្នុងឯណេះ"។

នាងយកក្មេងប្រុសនោះចូលខាងក្នុង រួចដាក់គាត់ចុះក្នុងកន្លែងដែលនៅខាងមុខដែលមានភ្លើងសំរាប់អាំងពេលរងារ ហើយបានចេញពីក្មេងនោះទៅ។ ក្មេងនោះបានអង្គុយនៅទីនោះមួយស្របក់ហើយគិតខ្លួនឯងគម្ពីរ *យ៉ូហាន៣:១៦-ខ្ញុំមិនយល់ទេប៉ុន្តែវាពិតជាបានធ្វើឱ្យក្មេងប្រុសចេញពីកន្លែងដែលត្រជាក់មកកន្លែងដែលកក់ក្តៅបាន។*

បន្ទាប់មកនាងបានត្រឡប់មកវិញសួរក្មេងប្រុសនោះថា "ក្អួយឃ្លានហើយឬនៅ?"

ក្មេងនោះបាននិយាយថា "បាទ ឃ្លានបន្តិចបន្តួចដែរ។ ខ្ញុំមិនបានទទួលទានអ្វីពីរបីថ្ងៃហើយ ហើយខ្ញុំជឿថា ខ្ញុំអាចទទួលទានអាហារបានតែបន្តិចបន្តួចប៉ុណ្ណោះ។" ស្ត្រីនោះបានយកក្មេងនោះទៅកាន់ផ្ទះបាយ រួចដាក់ឱ្យអង្គុយនៅមុខតុបាយដែលពេញទៅដោយម្ហូបដ៏ឆ្ងាញ់ៗ ហើយក្មេងនោះបានញ៉ាំហើយញ៉ាំទៀត ទាល់តែញ៉ាំលែងចូល។ បន្ទាប់មកទៀត ក្មេងនោះបានគិតខ្លួនឯងទៀត *យ៉ូហាន៣:១៦ ខ្ញុំមិនយល់ទេ តែវាពិតជាបាន ធ្វើឱ្យក្មេងប្រុសម្នាក់ដែលស្រេកឃ្លានបានឆ្អែត។*

នាងបានយកក្មេងនោះឡើងទៅជាន់លើ ទៅកាន់បន្ទប់គេងដែលមានអាងមុជទឹកធំមួយពេញដោយទឹកក្តៅឧណ្ហៗ។ក្មេងនោះបានអង្គុយត្រាំក្នុងនោះមួយស្របក់។ពេលកំពុងតែត្រាំ ក្មេងនោះបានគិតខ្លួនឯង *យ៉ូហាន៣:១៦ខ្ញុំមិនយល់ទេ តែវាពិតជាបានធ្វើឱ្យក្មេងប្រុសកខ្វក់ម្នាក់បានស្អាតវិញ។* ស្ត្រីបានចូលមកខាងក្នុងនោះ ហើយយកក្មេងប្រុសនោះចេញទៅដាក់ក្នុងបន្ទប់មួយនិងដាក់នៅលើគ្រែរោមសត្វហើយបានដាក់រោមសត្វជុំវិញកក្មេងនោះទាំងថើបលានាពេលរាត្រីទៀតផង។ ក្រោយមកនាងក៏បានបិទភ្លើងកេង។ នៅពេលដែលក្មេងនោះទម្រេតទៅលើគ្រែទាំងងងឹត ក្មេងនោះបានមើលទៅតាមបង្អួច ហើយឃើញព្រិលធ្លាក់ចុះក្រោមនាយប់ដ៏ត្រជាក់នោះ។ ក្មេងប្រុសនោះបានគិតខ្លួនឯងទៀត *យ៉ូហាន៣:១៦ ខ្ញុំមិនយល់ទេតែវាពិតជាបានធ្វើឱ្យក្មេងប្រុសដែល*

# នេះជាពេលសំរាប់ការចុះចូល

*អស់កម្លាំងបានសំរាក ។*

ព្រឹកបន្ទាប់ នាងបានយកក្មេងប្រុសនោះចុះក្រោមម្តងទៀត ទៅដាក់មុខតុដែលពេញទៅដោយអាហារ ។ បន្ទាប់ពីក្មេងប្រុសនោះបានបរិភោគរួចហើយ នាងបានយកក្មេងនោះទៅដាក់មុខកន្លែងអាំងភ្លើងម្តងទៀត ។ នាងបានយកគម្ពីរមកហើយនិយាយថា "តើក្មួយយល់*យ៉ូហាន៣:១៦*ឬទេ?" ។ "ទេ, ខ្ញុំមិនយល់ទេ វាជាលើកទីមួយដែលខ្ញុំបានឮ គឺយប់មិញ នៅពេលដែលលោកប៉ូលីសម្នាក់បាននិយាយមកកាន់ខ្ញុំ ហើយឱ្យខ្ញុំយកមកនិយាយតាម ។" នាងបានបើកព្រះគម្ពីរយ៉ូហាន៣:១៦ ហើយចាប់ផ្តើមពន្យល់ក្មេងនោះអំពីព្រះយេស៊ូ ។ នៅចំពីមុខកន្លែងអាំងភ្លើងនោះ ក្មេងប្រុសនោះបានប្រគល់ចិត្ត និង ជីវិតរបស់ខ្លួនថ្វាយព្រះយេស៊ូ ។ ក្មេងប្រុសនោះអង្គុយនៅទីនោះ ហើយគិត *យ៉ូហាន៣:១៦ ខ្ញុំមិនយល់ទេតែវាពិតជាធ្វើឱ្យក្មេងប្រុសដែលបានវង្វេងមានអារម្មណ៍ថា សុវត្ថិភាព - (គ្មានឈ្មោះអ្នកនិពន្ធ) ។*

ពេលនេះ ប្រសិនបើអ្នករួចរាល់ក្នុងការថ្វាយជីវិតរបស់អ្នកដល់ព្រះជាម្ចាស់ ដោយការទទួលព្រះយេស៊ូគ្រិស្ត ជាព្រះបុត្រារបស់ព្រះអង្គ ដូចជាទទួលយកនូវការសងថ្លៃនៃអំពើបាបរបស់អ្នកតែមួយគត់ ខ្ញុំសូមលើកទឹកចិត្តអ្នកឱ្យអធិស្ឋានជាមួយនឹងខ្ញុំ ។ បន្ទរតាមពាក្យឱ្យខ្លាំងៗ ហើយស្តាប់ដោយយកចិត្តទុកដាក់ នោះនឹងពិតជាមានន័យសំរាប់អ្នកដោយផ្ទាល់ ។

*ព្រះបិតាជាម្ចាស់ ទូលបង្គំស្រឡាញ់ព្រះអង្គ ។ ទូលបង្គំចូលមកកាន់ព្រះអង្គថ្ងៃនេះដោយជំនឿ ដើម្បីសុំព្រះអង្គមេត្តាអត់ទោសរាល់អំពើបាបរបស់ទូលបង្គំ ។ ព្រះយេស៊ូ ទូលបង្គំជឿលើព្រះអង្គហើយ ទូលបង្គំជឿថាព្រះអង្គបានសុគតនៅលើឈើឆ្កាងសំរាប់ទូលបង្គំ ព្រះអង្គបានកំចាយព្រះលោហិតដែលគ្មានទោសសោះ របស់ព្រះអង្គសំរាប់ទូលបង្គំ ព្រះអង្គបានរងទុក្ខទោសដែលសាកសមនឹងទូលបង្គំទទួលជំនួសទូលបង្គំវិញ ទូលបង្គំជឿថាព្រះអង្គបានសុគត ហើយត្រូវបានគេយកទៅបញ្ចុះក្នុងផ្នូរ រួចនៅថ្ងៃទីបីព្រះអង្គបានមានព្រះជន្មរស់ឡើងវិញពីសេចក្តីស្លាប់ ។សេចក្តីស្លាប់ពុំអាចបង្ឃាំងព្រះអង្គទុកបានឡើយ ។ ព្រះអង្គបានមានជ័យជំនះលើសាតាំង ហើយថែមទាំងបាន*

*យកនូវកូនសោរស្ថាននរក និងសេចក្តីស្លាប់ចេញពីទូលបង្គំ ។ ទូលបង្គំជឿថាព្រះអង្គបានធ្វើការទាំងនេះសំរាប់ទូលបង្គំពិត ព្រោះព្រះអង្គស្រឡាញ់ទូលបង្គំ ។ ទូលបង្គំចង់ក្លាយជាគ្រិស្តបរិស័ទដែរ ។ ទូលបង្គំចង់បំរើព្រះអង្គអស់មួយជីវិតរបស់ទូលបង្គំ ។ ទូលបង្គំចង់រស់នៅរបៀបថ្មីដែលព្រះអង្គបានសន្យានឹងទូលបង្គំ ។ ទូលបង្គំទទួលព្រះអង្គព្រះយេស៊ូនៅពេលនេះ ហើយទូលបង្គំថ្វាយជីវិតនឹងរូបកាយរបស់ទូលបង្គំ ដល់ព្រះអង្គវិញ ។ សូមទទួលទូលបង្គំក្នុងមាគ៌ារបស់ទ្រង់ផង ហើយថ្មែទូលបង្គំតាមព្រះហប្ញទ័យរបស់ព្រះអង្គដែរ ។*

*សូមអរគុណព្រះយេស៊ូដែលព្រះអង្គសង្គ្រោះទូលបង្គំ ។ សូមបំពេញទូលបង្គំដោយព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ ហើយបង្រៀនទូលបង្គំគ្រប់យ៉ាងដែលទូលបង្គំត្រូវដឹង ។ ពេលនេះទូលបង្គំជឿថា ទូលបង្គំបានសង្គ្រោះហើយ ទូលបង្គំបានកើតជាថ្មីម្តងទៀត ហើយទូលបង្គំនឹងទៅស្ថានសួគ៌នៅពេលដែលទូលបង្គំលាចាកលោកនេះទៅ ។ ព្រះបិតាជាម្ចាស់ ទូលបង្គំនឹងរីករាយជាមួយនឹងដំណើរជីវិតរបស់ទូលបង្គំ ហើយរស់នៅសំរាប់ជាការថ្វាយសិរីរុងរឿងដល់ព្រះអង្គ!*

ប្រសិនបើអ្នកបានអធិស្ឋានតាមសេចក្តីខាងលើនេះដោយស្មោះត្រង់មែន អ្នកពិតជាបានធ្វើការសំរេចចិត្តដ៏សំខាន់បំផុតនៅក្នុងជីវិតរបស់អ្នក ។ មិនថាអ្នកមានអារម្មណ៏យ៉ាងណានោះទេ ព្រះជាម្ចាស់បានស្តាប់ឮនូវសេចក្តីដែលអ្នកបានអធិស្ឋាន ហើយបានឆ្លើយតបមកវិញហើយ ។ អ្នកអាចនឹងមានអារម្មណ៏ថា មានសន្តិភាព ឬ រីករាយ ធូរស្បើយឬមានសេរីភាព ហើយអ្នកអាចគ្មានអារម្មណ៏អ្វីទាំងអស់ក៏ថាបាន ។ កុំអនុញ្ញាតឱ្យអារម្មណ៏របស់អ្នកដឹកនាំជីវិតរបស់អ្នកតទៅមុខទៀតឡើយ ។ ចូរជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ពីព្រោះព្រះអង្គស្មោះត្រង់ទៅនឹងសេចក្តីសន្យារបស់ទ្រង់ ។ ព្រះអង្គទ្រង់បានមានព្រះបន្ទូលថា: *អស់អ្នកដែលព្រះបិតាប្រទានមកខ្ញុំតែងតែមករកខ្ញុំ ហើយខ្ញុំមិនបោះបង់ចោលអ្នកដែលមករកខ្ញុំជាដាច់ខាត (ខ្ញុំនឹងមិនដែលបដិសេធអ្នកដែលមករកខ្ញុំជាដាច់ខាត) យ៉ូហាន ៦:៣៧ ។*

ព្រះជាម្ចាស់បានសន្យាថា ទ្រង់នឹងគង់នៅជាមួយអ្នករហូតតទៅ សូម្បីតែនៅទី

# នេះជាពេលសំរាប់ការចុះចូល

បញ្ចប់នៃផែនដីក៏ដោយ។ អ្នកអាចនឹងមិនដែលមានអារម្មណ៍ពីព្រះអង្គមែន ក៏ប៉ុន្តែព្រះអង្គគង់នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។ ព្រះអង្គតែងតែទតរំពៃមើលអ្នក ហើយមើលថែអ្នកផងដែរ។ ព្រះអង្គយកព្រះទ័យទុកដាក់នូវអ្វីដែលទាក់ទងនឹងអ្នក ហើយបានសន្យាថានឹងធ្វើឱ្យការទាំងនោះល្អប្រសើរឡើង។ ព្រះអង្គបានចាប់ផ្តើមការល្អនៅក្នុងអ្នក ហើយព្រះអង្គនឹងបង្ហើយការនោះ ទាំងសំរេចយ៉ាងពេញលេញទៀតផង (លោកុប្បត្តិ ២៨:១៥, ទំនុកតម្កើង១៣៨:៨, ភីលីព ១:៦)។

សូមអបអរសាទរ អ្នកមានមិត្តសំឡាញ់ថ្មី-ព្រះយេស៊ូ-ជាមិត្តដែលនឹងនៅជាមួយអ្នករហូត។ អ្នកអាចនិយាយទៅកាន់ព្រះអង្គនូវការគ្រប់យ៉ាងទាំងអស់ ពីព្រោះព្រះអង្គតែងតែយល់អ្នកយ៉ាងច្បាស់(ហេព្រើ៤:១៥)។ ព្រះអង្គមិនដែលបដិសេធ ឬដាក់ទោសអ្នកឡើយ។ គ្មានអ្វីដែលធំសំរាប់ព្រះជាម្ចាស់ទេ ហើយក៏គ្មានអ្វីតូចពេកសំរាប់ព្រះអង្គដែរនៅក្នុងការទាំងនេះ។ ព្រះអង្គចង់អោយអ្នកទទួលស្គាល់ព្រះអង្គគ្រប់ពេល ហើយអញ្ជើញព្រះអង្គទៅក្នុងគ្រប់ទីកន្លែងនៃជីវិតរបស់អ្នក។

អ្នកបានក្លាយទៅជាជីវិតថ្មីមួយទៀត។ការចាស់ទាំងប៉ុន្មានបានកន្លងផុតទៅហើយ គ្រប់ទាំងអស់ក៏ក្លាយទៅថ្មីដែរ(២កូរិនថូស៥:១៧)។ អ្នកចាប់ផ្តើមចេញពន្លកថ្មី។

អ្នកនឹងធ្វើខុស-ជាការពិតយើងតែងតែធ្វើខុស។ អ្នកមានការធំដែលត្រូវរៀន ហើយចាប់ផ្តើមដំណើរដែលនឹងបញ្ចប់ដោយខ្សែនៃជីវិតចុងក្រោយ។ ត្រូវតែចងចាំជានិច្ចថានៅពេលដែលអ្នកធ្វើខុស ការអត់ទោសនិងការសំអាតរបស់ព្រះអង្គ នៅតែមានសំរាប់អស់អ្នកដែលទូលអង្វរសូមទ្រង់។ ចូរប្រញាប់ប្រែចិត្តពីគ្រប់អំពើបាប ហើយមិនត្រូវព្យា យាមលាក់បាំងអ្វីមួយពីទ្រង់ឡើយពីព្រោះព្រះទ្រង់ជ្រាបគ្រប់យ៉ាង។

ព្រះអង្គស្រឡាញ់អ្នកខ្លាំងណាស់, ទ្រង់ស្រឡាញ់អ្នកគ្រប់ពេលវេលា។ ព្រះអង្គទ្រង់មិនស្រឡាញ់អ្នកច្រើននៅពេលដែលអ្នកធ្វើល្អ ហើយស្រឡាញ់អ្នកតិចនៅពេលណាដែលអ្នកធ្វើការអាក្រក់នោះទេ។ តែព្រះអង្គស្រឡាញ់អ្នក!

ពេលនេះជាពេលដែលត្រូវបង្រៀនអំពីរបៀបរស់នៅបែបថ្មី។

# ជំពូក ៤

## របៀបរស់នៅបែបថ្មី

កាលណាអ្នកចូលមករស់នៅក្នុងជីវិតថ្មី គឺមានន័យថា ត្រូវរស់នៅដោយសារព្រះជាម្ចាស់ ជាមួយព្រះជាម្ចាស់ និងសំរាប់ព្រះជាម្ចាស់ ។ អ្នកនឹងរកឃើញលក្ខណៈសំខាន់របស់ទ្រង់ ដែលមានភាពផ្ទុយគ្នាទៅនឹងលក្ខណៈនៃលោកិយនេះ ។ ការពិតទៅ លោកិយនេះទេដែលក្រឡាប់ចាក់ ផ្លាស់ប្តូរខ្លួនឯង ឯព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺនៅរឹងមាំ និងស្ថិតស្ថេរដដែល ។ យើងនៅមិនទាន់ស៊ាំថ្មីកទៅនឹងផ្លូវរបស់ព្រះជាម្ចាស់នៅឡើយទេ ដំបូងវាហាក់បីដូចជាមានការពិបាក ឬ ពិបាកយល់បន្តិច ។

## ការជ្រមុជ

ការមួយដែលអ្នកគួរធ្វើដូចជាគ្រិស្តបរិស័ទជឿថ្មីនៅក្នុងព្រះយេស៊ូគ្រិស្តនោះ គឺការទទួលពិធីជ្រមុជទឹក ។ ការជ្រមុជទឹកគឺជាការដែលបង្ហាញអំពីលក្ខណៈខាងក្រៅនៃការសំរេចចិត្តខាងក្នុងដើម្បីដើរតាមព្រះគ្រិស្តរបស់អ្នក ។ នៅពេលដែលមនុស្សជ្រមុជចូលទៅក្នុងទឹក គឺមានន័យថាកំពុងកប់ជីវិតចាស់របស់ខ្លួន ។ នៅពេលដែលគេងើបចេញមកវិញមានន័យថាជាការរស់ឡើងវិញក្នុងជីវិតថ្មី ។ ការទាំងនេះយើងធ្វើឡើងជាការគោរពចុះចូលនឹងព្រះជាម្ចាស់ ។

*នេះជានិមិត្តរូបនៃពិធីជ្រមុជទឹក(នៃការរំដោះ) ដែលសង្គ្រោះ(ពីភាពសង្ស័យនៃផ្នែកខាងក្នុងនិងភាពភ័យខ្លាច) បងប្អូននាបច្ចុប្បន្នកាល តែពិធីជ្រមុជទឹកមិនមែនជាពិធីលាងជំរះរូបកាយនោះទេ គឺជាការថ្វាយជីវិតទាំងស្រុងទៅព្រះជាម្ចាស់ (ផ្តល់ឱ្យអ្នកជាមួយ) ដោយមនសិការល្អវិញ ។ ពិធីជ្រមុជទឹកនេះ សង្គ្រោះបងប្អូនដោយសារព្រះ*

## របៀបរស់នៅបែបថ្មី

*យេស៊ូគ្រិស្តមានព្រះជន្មរស់ឡើងវិញ ។ (១ពេត្រុស ៣:២១)*

*លោកពេត្រុសមានប្រសាសន៍ទៅគេថា សូមបងប្អូនកែប្រែចិត្តគំនិត ហើយម្នាក់ៗត្រូវទទួលពិធីជ្រមុជទឹកក្នុងព្រះនាមព្រះយេស៊ូគ្រិស្តទៅ ដើម្បីព្រះជាម្ចាស់លើកលែងទោសបងប្អូនឱ្យរួចពីបាប ហើយបងប្អូននឹងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាព្រះអំណោយទានរបស់ព្រះជាម្ចាស់ ។ (កិច្ចការ ២:៣៨)*

## ការនៅព្រះវិហារ

ការផ្សេងទៀតដែលខ្ញុំត្រូវណែនាំខ្លាំងនោះគឺ ការចូលរួមនៅក្នុងពួកជំនុំក្នុងស្រុក ។ ការទៅព្រះវិហារមិនបានធ្វើឱ្យគ្រិស្តបរិស័ទប្រសើរជាង ការអង្គុយលេងក្នុងរោងឡានដើម្បីធ្វើវានោះទេ ។យើងមិនមែនក្លាយជាគ្រិស្តបរិស័ទល្អ ដោយការចូលក្នុងព្រះវិហារធម្មតាៗនោះឡើយ ក៏ប៉ុន្តែប្រសិនបើយើងជាគ្រិស្តបរិស័ទពិត យើងពិតជាចង់ថ្វាយបង្គំព្រះជាម្ចាស់ និងមានការប្រកបគ្នាជាមួយនឹងអស់អ្នកដែលជឿផ្សេងៗទៀតដែរ ។ ព្រះវិហារក៏ជាទីកន្លែងមួយដែលយើងរៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ ។

មិនមែនគ្រប់ព្រះវិហារសុទ្ធព្រះវិហារល្អទាំងអស់នោះទេ ។វិហារខ្លះមានអាគារធំៗបែបសាសនា មើលពីខាងក្រៅហាក់ដូចជាល្អ ប៉ុន្តែពិតគ្មានអ្វីទាល់តែសោះនៅខាងក្នុងដែលអាចជួយមនុស្សគ្រប់គ្នាបាន ។ ប្រសិនបើអ្នកចូលរួមវិហារដែលមិនបំប៉នអ្នកដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ ហើយបែរជាទប់ស្កាត់អ្នកពីការលូតលាស់រៀងរាល់ថ្ងៃក្នុងការដើរជាមួយនឹងព្រះជាម្ចាស់វិញ ចូរខំស្វែងរកវិហារមួយផ្សេងទៀតដែលត្រឹមត្រូវសំរាប់អ្នក។ ព្រះវិហារប្រៀបដូចជា វេជ្ជបណ្ឌិត មិនល្អទាំងអស់នោះទេ ហើយក៏មិនមែនអាក្រក់ទាំងអស់នោះដែរ ។ អ្នកគ្រាន់តែស្វែងរកព្រះវិហារមួយណាដែលត្រឹមត្រូវសំរាប់អ្នកដោយផ្ទាល់ ។មនុស្សខ្លះចូលចិត្តវិហារធំៗ ហើយក៏មានមនុស្សខ្លះផ្សេងទៀតចូលចិត្តវិហារតូចៗដែរ ។ព្រះវិហារខ្លះជានិយកាយមួយ ហើយចង់ឱ្យនិ

កាយខ្លួនខ្ពស់ជាងនិកាយផ្សេងទៀត ហើយមានមនុស្សខ្លះទៀតចង់ទៅព្រះវិហារដែលគ្មាននិកាយ ដែលមានន័យធម្មតាថា ពួកគេមិនមែនជាកម្មសិទ្ធិរបស់អង្គការធំៗណាមួយទេ។ ចំណុចសំខាន់នោះគឺថា ប្រសិនបើអ្នកមានព្រះវិហារដ៏ជាប់លាប់មួយនោះទើបជាការប្រសើរ។ វាផ្តល់ឱ្យអ្នកនូវឱកាសដើម្បី បង្កើតមិត្តភ័ក្រ្តដែលមានចិត្តដូចគ្នាខាងឯជំនឿរបស់អ្នកកាន់តែច្រើន ហើយដើម្បីចូលរួមក្នុងសង្គមនៅក៏រិតសីលធម៌មួយដែលនឹងជួយអ្នកឱ្យបានជៀសផុតពីសេចក្តីល្បួងទាំងឡាយរបស់លោកិយ។

ចូរឱ្យប្រាកដថា អ្នកទៅព្រះវិហារណាមួយដែលអ្នកមានអារម្មណ៏ថា នឹងឱ្យអ្នកលូតលាស់ក្លាយទៅជាគ្រិស្តបរិស័ទដ៏ល្អម្នាក់។ វាជាការសំខាន់ណាស់សំរាប់អ្នកជឿថ្មីក្នុងការរៀននូវកិច្ចការជាច្រើន។ ប្រសិនបើគេមិនបានរៀន ហើយមិនមានការរីកលូតលាស់ទេ នោះគេស្ថិតនៅក្នុងភាពគ្រោះថ្នាក់មួយនៃការប្រព្រឹត្តអំពើបាបឡើងវិញ ឬក៏ត្រឡប់ទៅផ្លូវចាស់របស់គេដដែលវិញ។

ការសិក្សាព្រះគម្ពីរតាមក្រុមតូច មានប្រយោជន៏យ៉ាងខ្លាំងសំរាប់អ្នកជឿថ្មី។ ជាធម្មតានៅក្នុងក្រុមតូច អ្នកនឹងមានឱកាសដើម្បីរៀន, សួរសំណួរ, ទទួលការអធិស្ឋានឱ្យគ្នា ហើយនិងមានចំណែកអធិស្ឋានឱ្យអ្នកដទៃទៀតផងដែរ។ ដោយសង្ឃឹមថា ព្រះវិហាររបស់អ្នកនឹងផ្តល់នូវថ្នាក់សិក្សាព្រះគម្ពីរសំរាប់មនុស្សធំពេញវ័យ ឬក៏ក្រុមកោសិការតាមផ្ទះដែលអ្នកអាចមានចំណែក។ ព្រះវិហារមិនមែនគ្រាន់តែជាទីកន្លែងសំរាប់ថ្វាយបង្គំប៉ុណ្ណោះទេ ប៉ុន្តែព្រះវិហារក៏ជាទីកន្លែងសំរាប់ឱ្យយើងស្វែងរក និងបង្ហាញនូវព័ន្ធកិច្ចរបស់យើងក្នុងរូបកាយព្រះគ្រិស្តផងដែរ(ពួកជំនុំ)។ ក្រៅពីការទទួលពីអ្នកដទៃ, អ្នកក៏ត្រូវតែចេះចែកចាយដល់អ្នកដទៃវិញដែរ។

## ការប្តូរផ្តាច់

ការមានភាពច្បាស់លាស់គឺជាការសំខាន់បំផុត។ វាមិនមែនជាអ្វីដែលយើងបាន

ធ្វើខុសម្តងហើយធ្វើឱ្យជីវិតរបស់យើងធ្លាក់ទៅក្នុងភាពច្របូកច្របល់នោះទេ វាគឺជាអ្វីដែលយើងបានធ្វើខុសដដែលៗ។ ហើយការធ្វើអ្វីមួយត្រឹមត្រូវមួយដង ឬ ពីរដងក៏នឹងមិនអាចជួយយើងឱ្យរស់នៅក្នុងជីវិតថ្មីដែលព្រះជាម្ចាស់បានប្រទានឱ្យយើងបានដែរ។ យើងត្រូវតែមានសេចក្តីខ្ជាប់ខ្ជួនហើយធ្វើអ្វីដែលយើងដឹងថាគួរតែធ្វើ បើទោះជាពេលខ្លះយើងមិនមានអារម្មណ៍ចង់ធ្វើការនោះក៏ដោយ ។យើងត្រូវតែរឹងមាំ។ *"ដ្បិតព្រះទ្រង់មិនបានប្រទានឱ្យយើងមានវិញ្ញាណ ដែលតែងតែខ្លាចឡើយ គឺឱ្យមានវិញ្ញាណដ៏មានអំណាចសេចក្តីស្រឡាញ់ និងប្រាជ្ញានឹងធឹងវិញ"* ។(២.ធីម៉ូថេ១:៧)

ចូរឱ្យច្បាស់លាស់ក្នុងការចំណាយពេលជាមួយព្រះជាម្ចាស់។ សិក្សាព្រះបន្ទូលព្រះ ហើយអានសៀវភៅណាដែលជួយអ្នកឱ្យយល់អំពីព្រះគម្ពីរកាន់តែច្បាស់ថែមទៀត។ ស្តាប់ការបង្រៀនតាមកាសែត ម៉ាញ៉េ, ស៊ីឌី ឬ មើលកម្មវិធីទូរទស្សន៍គ្រីស្ទានផ្សេងៗជាដើម។ ចំណាយពេលវេលាខ្លះអធិស្ឋាន។ រៀនអធិស្ឋានតាមរបៀបខ្លួនឯងរាល់ថ្ងៃ។ អ្នកត្រូវចងចាំថាព្រះជាម្ចាស់តែងតែចាប់អារម្មណ៍នូវគ្រប់ ហេតុការណ៍ទាំងអស់ដែលនាំឱ្យអ្នកមានកង្វល់ ហើយការអធិស្ឋានគឺជាវិធីដ៏ល្អក្នុងការសន្ទនាជាមួយទ្រង់។ នៅពេលដែលអ្នករីកលូតលាស់ជាគ្រិស្តបរិស័ទម្នាក់ អ្នកមិនត្រឹមតែត្រូវរៀនពីរបៀបនិយាយទៅកាន់ព្រះជាម្ចាស់ប៉ុណ្ណោះនោះទេ អ្នកត្រូវរៀនអំពី របៀបស្តាប់សម្លេងរបស់ព្រះជាម្ចាស់ផងដែរ ហើយការនេះនឹងបន្ថែមនូវភាពរំភើបដល់អ្នកក្នុងការដើរជាមួយព្រះជាម្ចាស់។

សារៈសំខាន់បំផុតមួយផ្សេងទៀតដែលតម្រូវនោះគឺការថ្វាយ។ ព្រះជាម្ចាស់បានប្រទានឱ្យយើងយ៉ាងច្រើនក្រៃលែងដែលជាតម្រូវការតាំងពីកំណើតរបស់យើង ហើយទ្រង់ចង់ឱ្យយើងចេះថ្វាយដល់ទ្រង់ និងកិច្ចការរបស់ទ្រង់នៅលើផែនដីនេះវិញ។ នៅពេលដែលអ្នកធ្លាប់ត្រូវបានគេជួយ នោះទ្រង់ក៏ចង់ឱ្យអ្នកជួយគេវិញដែរ ហើយវិធីដ៏

ល្អមួយនោះគឺតាមរយៈការថ្វាយយ៉ាងទៀងទាត់ដល់ព្រះវិហាររបស់អ្នក និងព័ន្ធកិច្ចដែលបានជួយអ្នក ហើយអ្នកជឿជាក់។ គ្រប់អ្វីៗដែលយើងថ្វាយដល់ព្រះជាម្ចាស់, នោះទ្រង់ប្រទានឱ្យយើងវិញច្រើនលើសហ្នឹងទៅទៀត។ ព្រះអង្គបានមានបន្ទូលថា អ្វីដែលយើងព្រោះចុះ នោះយើងនឹងច្រូតកាត់វិញ។

ការទទួលយកព្រះគ្រិស្តដំបូង និង ការក្លាយជាអ្នកជឿថ្មីម្នាក់ក្នុងទ្រង់, យើងមិនចាប់អារម្មណ៍ខ្លាំងលើការថ្វាយនោះទេ។ពួកយើងម្នាក់ៗសុទ្ធតែអាត្មានិយម ហើយចង់ឱ្យតែអ្នកផ្សេងផ្តល់ឱ្យយើងវិញប៉ុណ្ណោះ, ប៉ុន្តែចិត្តយើងម្នាក់ៗនឹងផ្លាស់ប្តូរវិញ ពេលយើងនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះយេស៊ូកាន់តែជ្រៅទៅៗ។

## ការជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ

ការជ្រមុជមានន័យថា ការធ្វើអ្វីមួយឱ្យលិចទាំងស្រុង។ អ្វីៗដែលត្រូវបានជ្រមុជលិចបាត់ទៅគឺត្រូវបានចាក់បំពេញប្រសិនបើមានការបើកចំហ។ បើអ្នកបើកចំហ នោះអ្នកក៏អាចបំពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធបានដែរ។ អ្នកក៏ទទួលបានព្រះវិញ្ញាណបរិសុទ្ធនៅពេលអ្នកទទួលព្រះយេស៊ូជាព្រះអង្គសង្គ្រោះរបស់អ្នក ប៉ុន្តែប្រហែលជាអ្នកមិនទាន់ដល់កំរិតមួយដែលអ្នកបានរួចរាល់ក្នុងការចំហចិត្តដើម្បីឱ្យទ្រង់ចាក់បំពេញអ្នកនៅឡើយទេ។

អ្នកមានព្រះវិញ្ញាណបរិសុទ្ធហើយ ប៉ុន្តែអ្នកចង់ឱ្យប្រាកដថាទ្រង់មានអ្នកវិញដែរ។ ព្រះជាម្ចាស់ចង់ប្រើអ្នកឱ្យធ្វើកិច្ចការថ្វាយទ្រង់ ហើយអ្នកនឹងត្រូវការអំណាចព្រះវិញ្ញាណរបស់ទ្រង់ ដើម្បីជួយអ្នកឱ្យទទួលជោគជ័យនិងមានផលិតភាព។

ព្រះជាម្ចាស់ក៏ប្រទាននូវអំណោយទានដ៏ពិសេសដល់យើង (ថាមពលនិងអំណោយទានលើសពីធម្មជាតិ) ដើម្បីជួយយើងឱ្យរស់នៅក្នុងជីវិតប្រចាំថ្ងៃ។ អំណោយទានទាំងឡាយរបស់យើងម្នាក់ៗគឺខុសៗគ្នា ហើយយើងម្នាក់ៗសុទ្ធតែបានទទួលអំណោយទាន

នោះ តែអ្នកខ្លះប្រហែលជាមានសមត្ថភាពខ្ពស់ជាងអ្នកដទៃទៀត។ ខ្ញុំត្រូវបានព្រះអង្គប្រទាននូវអំណោយទានខាងការបង្រៀន ហើយអ្នកផ្សេងទៀតមានអំណោយទានខាងភ្លេង ឬខាងការគ្រប់គ្រងជាដើម,ដែលការទាំងអស់នេះសុទ្ធតែមកពីការសណ្ដោសប្រណីនិងជួយជ្រោមជ្រែងពីព្រះជាម្ចាស់ទាំងអស់។ មានអំណោយទានប្រាំបួនយ៉ាងនៅក្នុងគម្ពីរ១កូរិនថូស១២:៧-១០ "[៧] *ហើយទ្រង់ប្រទានដើម្បីឱ្យបានកើតផល [៨] ត្បិតទ្រង់ប្រទានឱ្យម្នាក់មានប្រាជ្ញាវាងវៃដោយសារព្រះវិញ្ញាណ ឱ្យម្នាក់ទៀតមានពាក្យសំដីនៃចំណេះចេះស្ទាត់តាមព្រះវិញ្ញាណដដែល [៩] ហើយឱ្យម្នាក់ទៀតមានសេចក្ដីជំនឿដោយនូវព្រះវិញ្ញាណដដែល ឱ្យមួយទៀតបានអស់ទាំងអំណោយ ទាននិងអាចប្រោសឱ្យជាដោយនូវព្រះវិញ្ញាណដដែល [១០] ឱ្យម្នាក់ទៀតបានសំដែងការឫទ្ធិបារមី និងឱ្យមួយទៀតចេះអធិប្បាយ ឱ្យមួយទៀតសង្កេតស្គាល់អស់ទាំងវិញ្ញាណ ឱ្យមួយទៀតចេះនិយាយភាសាដទៃផ្សេងៗ ហើយឱ្យមួយទៀតចេះបកប្រែភាសាដទៃ*"

បើទោះជាអ្នកមិនបានយល់នូវអំណោយទានទាំងនេះ, ខ្ញុំសូមលើកទឹកចិត្តអ្នកឱ្យទូលសុំអំណោយទាននោះពីព្រះ ហើយបង្រៀនអ្នកឱ្យចេះប្រើអំណោយទានទាំងនោះដើម្បីឱ្យមានបានល្អប្រសើរនិងត្រឹមត្រូវ។ យើងឃើញមានការជំនួសព្រះបន្ទូលព្រះជាច្រើនរបស់មនុស្សដែលនិយាយមិនដឹងភាសាដទៃ(ភាសារបស់ព្រះវិញ្ញាណ)។ នៅពេលដែលយើងអធិស្ឋានជាភាសាដទៃ នោះយើងកំពុងតែនិយាយភាសាសំងាត់ និងអាថិកំបាំងទៅកាន់ព្រះជាម្ចាស់ ហើយយើងអភិវឌ្ឍន៍ខ្លួននិងកសាងខ្លួនយើងតាមការនេះដែរ។ លោកសាវ័កប៉ុលបាននិយាយថា ខ្ញុំចង់ឱ្យបងប្អូនចេះនិយាយភាសាដទៃអស្ចារ្យទាំងអស់គ្នា "។(១កូរិនថូស ១៤:២, ៤-៥)

អំណោយទានក្នុងការនិយាយភាសាដទៃ ជាទូទៅមានសំរាប់តែគ្រិស្ដបរិស័ទណាដែលបានជឿព្រះច្រើនឆ្នាំ។ អ្នកខ្លះជឿថាអំណោយទានគឺសំរាប់តែថ្ងៃនេះប៉ុណ្ណោះក្នុង

ខណៈអ្នកផ្សេងទៀតគេពុំបានជឿ ។ ខ្ញុំមានបទពិសោធន៍ផ្ទាល់ខ្លួនចំពោះអំណោយទានទាំងនេះក្នុងជីវិតរបស់ខ្ញុំ ហើយខ្ញុំធ្លាប់បាននិយាយភាសាព្រះវិញ្ញាណប្រហែលជាជាង ៣០ឆ្នាំ ។ ហេតុដូច្នោះហើយ ខ្ញុំដឹងថា វាមានការទាក់ទងគ្នាជាមួយនឹងបច្ចុប្បន្នភាពរបស់គ្រិស្តបរិស័ទ ។ យើងត្រូវការអ្វីដែលនឹងជួយយើងបាន ។

ជារឿយៗ មនុស្សជាច្រើនបានបដិសេធនឹនូវអ្វីដែលពួកគេមិនដែលធ្លាប់មានបទពិសោធន៍ ឬអ្វីដែលពួកគេមិនយល់ ។ នេះគឺជាកំហុសឆ្គង ។ យើងគួរតែអានគម្ពីរ ហើយជឿនូវអ្វីដែលព្រះគម្ពីរបានមានបន្ទូល ។

ខ្ញុំសូមដាស់តឿនឱ្យអ្នកផ្ចង់អារម្មណ៍ទៅលើព្រះវិញ្ញាណបរិសុទ្ធដោយខ្លួនឯង មិនមែនផ្ចង់តែទៅលើអំណោយទានរបស់ទ្រង់នោះទេ ។អំណោយទាននឹងប្រទានមកដល់ ។ មនុស្សមួយចំនួនបានអភិវឌ្ឍបន្ថែមទៅលើការនិយាយភាសាដទៃ ឬក៏អំណោយទានផ្សេងៗទៀតជាងដែលពួកគេអាចធ្វើបាន ។ នៅពេលយើងទៅទិញស្បែកជើងមួយគូ, យើងមិនបានទៅហាងលក់ស្បែកជើង ហើយសួរភាសាស្បែកជើងទេ ។ យើងសួររកស្បែកជើង ហើយពាក្យសំដីក៏ទៅតាមភាសាស្បែកជើងដែរ ។ វាគឺតែមួយទេជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ ។ ត្រូវទូលសូមរាល់តែថ្ងៃដើម្បីឱ្យយើងបានទទួលវត្តមានទ្រង់នៅក្នុងជីវិតរបស់យើង ហើយភាសាដទៃ និងអំណោយទានផ្សេងទៀតនឹងមកដល់អ្នកតាមពេលវេលា ។

## ចូរស្វែងរកព្រះវត្តមានរបស់ព្រះជាម្ចាស់, មិនមែនស្វែងរកអំណោយរបស់ទ្រង់នោះទេ

ព្រះជាម្ចាស់ចង់ធ្វើការល្អសំរាប់អ្នក ។ព្រះអង្គចង់ប្រទានពរជាច្រើនដល់យើងប៉ុន្តែវាជាការសំខាន់ណាស់ ដែលអ្នកស្វែងរកទ្រង់ថាតើទ្រង់ជានរណា ហើយមិនសង្ស័យថា

## របៀបរស់នៅបែបថ្មី

តើទ្រង់អាចធ្វើអ្វីបានខ្លះសំរាប់អ្នកនោះទេ។ ព្រះជាម្ចាស់ទ្រង់អស្ចារ្យហួសពីការស្មានគ្មានអ្វីប្រៀបផ្ទឹមបាន ហើយការរស់នៅក្នុងព្រះវត្តមានទ្រង់គឺអស្ចារ្យណាស់។ នៅពេលអ្នកស្វែងរកព្រះភ័ក្ត្រទ្រង់ នោះអ្នកនឹងឃើញថា ព្រះហស្តរបស់ទ្រង់តែងតែបើកចំហជានិច្ច។ ប៉ុន្តែបើអ្នកគ្រាន់តែស្វែងរកព្រះហស្តរបស់ទ្រង់ នោះវានឹងជាការប្រមាថដល់ទ្រង់វិញ។ គ្មាននរណា ម្នាក់សូម្បីតែព្រះជាម្ចាស់ ចង់ឱ្យគេប្រើប្រាស់សំរាប់តែគុណប្រយោជន៏ផ្ទាល់ខ្លួននោះទេ។

ចូរទូលសូមព្រះជាម្ចាស់ចំពោះការអ្វីដែលអ្នកចង់បាន ឬត្រូវការ ហើយប្រសិនបើការនោះជាការពិសេសរបស់អ្នក ដល់ពេលទ្រង់ នោះទ្រង់នឹងប្រទានដល់អ្នកជាមិនខាន ។ប៉ុន្តែចូរចងចាំជានិច្ចថាអ្នកត្រូវការព្រះអង្គជាងអ្វីៗទាំងអស់ក្នុងជីវិតរបស់អ្នក។ ចូរសូមព្រះវត្តមានទ្រង់, ផ្លូវរបស់ទ្រង់, បុគ្គលិកលក្ខណៈរបស់ទ្រង់, ប្រាជ្ញារបស់ទ្រង់, ការយល់ដឹងរបស់ទ្រង់ និងអំណាចព្រះចេស្តារបស់ទ្រង់ជាដើម។

ព្រះជាម្ចាស់គឺជាអ្វីៗទាំងអស់ ចំណែកយើងគឺមិនជាអ្វីទាំងអស់ប្រសិនបើមិនមានទ្រង់ទេនោះ។ ព្រះយេស៊ូបានមានព្រះបន្ទូលនៅគម្ពីរយ៉ូហាន១៥:៥ ថា *"ដ្បិតបើដាច់ចេញពីខ្ញុំ នោះអ្នករាល់គ្នាពុំអាចនឹងធ្វើអ្វីបានទេ"* ។

*រ៉ូម១១:៣៦ " ដ្បិតរបស់សព្វសារពើបានកើតមកពីទ្រង់ ដោយសារទ្រង់ ហើយសំរាប់ទ្រង់ សូមឱ្យទ្រង់បានសិរីល្អនៅអស់កល្បជានិច្ច អាម៉ែន ។ "*

## មានការជាច្រើនទៀតដែលត្រូវរៀន

មានការជាច្រើនណាស់ដែលអ្នកត្រូវរៀនបន្ថែមទៀតពីខ្ញុំ ដើម្បីចែកចាយការទាំងអស់នោះនៅក្នុងសៀវភៅតូចមួយនេះ។ អ្នកនឹងត្រូវរៀនបន្ថែមទៀតអំពីគោលលទ្ធិសេចក្តីជំនឿរបស់អ្នក ដែលមានមូលដ្ឋានគ្រឹះសំរាប់ការបង្រៀនថ្នាក់ដំបូងនៃគ្រិស្តសាសនា។ ថ្នាក់សំរាប់អ្នកជឿថ្មី ជាធម្មតាគឺផ្តោតទៅលើក្រុមជំនុំភាគច្រើនបំផុត,

## របៀបរស់នៅបែបថ្មី

ហើយខ្ញុំសូមផ្ដល់យោបល់ថា អ្នកត្រូវតែចូលរួមក្នុងថ្នាក់ណាមួយផងដែរ។ អ្នកនឹងបានរៀនថា ព្រះយេស៊ូបានប្រសូតចេញមកពីស្ត្រីព្រហ្មចារីហ៍។ ខ្ញុំដឹងថា ស្ដាប់ទៅវាមិនអាចទៅរួចនោះទេ, ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏វាជាសេចក្ដីពិត ហើយវាពិតជាមានសារៈសំខាន់សំរាប់អ្នកក្នុងការយល់អំពីមូលហេតុនេះ។ អ្នកនឹងបានរៀនថា តើវាមានសារៈសំខាន់យ៉ាងណាក្នុងការថ្វាយជាហិរញ្ញវត្ថុដល់ព្រះជាម្ចាស់វិញ ហេតុដូច្នេះដំណឹងល្អអាចចែកចាយដល់អ្នកដទៃទៀតដែលមិនទាន់បានស្គាល់ព្រះអង្គនៅឡើយ។ អ្នកនឹងបានរៀនអំពីព្រះត្រៃឯក, ព្រះនៃការបំរើដ៏ពិតមួយអង្គ ដែលមាននាមបីក្នុងអង្គតែមួយ គឺព្រះបិតា, ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ។ អ្នកនឹងបានរៀនអំពីព័ន្ធកិច្ចរបស់ទេវតាទាំងឡាយ, ពីសារៈប្រយោជន៍នៃព្រះលោហិតរបស់ព្រះយេស៊ូ, ពីរបៀបនៃការស្ដាប់ព្រះសូរសៀងរបស់ព្រះជាម្ចាស់, អំពីភាពសុចរិត, ពីការប្រែចិត្ត និងរៀនពីកិច្ចការជាច្រើនផ្សេងៗទៀត។

ទោះបីជាខ្ញុំមិនអាចចែកចាយនូវអ្វីគ្រប់យ៉ាង ឱ្យអស់សេចក្ដីនៅក្នុងកូនសៀវភៅមួយក្បាលនេះក៏ដោយ ក៏មានការមួយចំនួនទៀតដែលខ្ញុំចង់ចែកចាយ ហើយខ្ញុំជឿថាជាការសំខាន់ដ៏ចំបងសំរាប់ជីវិតថ្មីរបស់អ្នក។ សូមយើងបន្តដំណើរទៅខាងមុខទៀត។

# ជំពូក ៥

## របៀបគិតបែបថ្មី

ការព្យាយាមរៀនសញ្ជឹងគិតបែបថ្មីគឺជាការសំខាន់បំផុត។ ព្រះជាម្ចាស់មានផែនការដ៏ល្អសំរាប់រូបអ្នកនិងជីវិតរបស់អ្នក ប៉ុន្តែអ្នកត្រូវតែចុះចូលជាមួយកិច្ចព្រមព្រៀងជាមួយទ្រង់ទាក់ទងនិងបញ្ហានេះ។ អារក្សសាតាំង ក៏មានគំរោងផែនការសំរាប់អ្នកនិងជីវិតរបស់អ្នកផងដែរ តែផែនការនោះមិនល្អសំរាប់អ្នកទេ។ នៅក្នុងព្រះគម្ពីរ យ៉ូហាន១០:១០:"ចោរវាមកគិតតែពីលួចប្លន់ គិតតែពីសំឡាប់ និងបំផ្លាញប៉ុណ្ណោះ"។ សាតាំងបញ្ចូលគ្រប់ទាំងការគិតអាក្រក់ទាំងអស់ទៅក្នុងគំនិតរបស់យើងដោយសង្ឃឹមថាយើងនឹងជឿ ហើយយល់ព្រមធ្វើតាមវា។ នេះគឺជាវិធីសាស្ត្ររបស់មាសាតាំងក្នុងការល្បួងមនុស្ស ដើម្បីរកផ្លូវចូលទៅក្នុងជីវិតរបស់ពួកគេ។

ក្នុងព្រះគម្ពីររ៉ូម១២:២បានថែងថា:"មិនត្រូវយកតម្រាប់តាមលោកិយនេះឡើយ (អាយុនេះ) ,សម័យទំនើប និង លំនាំបញ្ចេញមកក្រៅ, ទំនាមទំលាប់ពេក ត្រូវទុកឱ្យព្រះជាម្ចាស់កែប្រែ(ផ្លាស់ប្តូរ) ចិត្តគំនិតបងប្អូនឱ្យទៅជាថ្មីទាំងស្រុងវិញ (ដោយគំនិត និង អាកប្បកិរិយាប្រែសារជាថ្មី) ដើម្បីឱ្យបងប្អូន ចេះពិចារណា (ជីវិតរបស់អ្នក)មើលថាព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្វីខ្លះ គឺអ្វីដែលល្អ ដែលគាប់ព្រះហឫទ័យព្រះអង្គ និងគ្រប់លក្ខណ៍។

បទគម្ពីរខាងលើបានបញ្ជាក់ប្រាប់យើងយ៉ាងច្បាស់ថា ជីវិតរបស់យើងនឹងមិនអាចផ្លាស់ប្តូរបានទេ ប្រសិនបើការគិតរបស់យើងមិនបានផ្លាស់ប្តូរនោះ។ បើអ្នកចង់បាន

របៀបរស់នៅបែបថ្មី

ជីវិតថ្មី អ្នកត្រូវតែមានការគិតបែបថ្មី។ ព្រះជាម្ចាស់មានផែនការដ៏ល្អសំរាប់ជីវិតយើងគ្រប់គ្នា ប៉ុន្តែយើងនឹងឃើញវាកន្លងទៅហួសដូចដែលយើងរៀនពីចំណុចសំខាន់នៃការគិតដ៏ត្រឹមត្រូវ។

## អ្នកអាចគ្រប់គ្រងការគិតរបស់អ្នកបាន

ប្រហែលជាអ្នកដូចខ្ញុំកាលពីមុនដែលធ្លាប់គិតថា អ្នកមិនអាចធ្វើអ្វីដែលអ្នកកំពុងតែគិតនោះបានទេ។ ការគិតបែបនេះវាមិនត្រឹមត្រូវទេ។អ្នកអាចជ្រើសរើសនូវអ្វីដែលគិត ឬ នឹងមិនគិតពីវា ហើយគួរតែធ្វើដោយប្រយ័ត្នបំផុត។ គំនិតទៅណា មនុស្សក៏ទៅទីនោះដែរ។ យើងធ្លាប់មានបទពិសោធន៏ជាច្រើនដែលទាក់ទងទៅនិងការគិតពីអ្វីដែលនឹងត្រូវបរិភោគ។ ប្រហែលជាការ៉េម នំដូណាត់ ឬអាហារដែលទាក់ទាញផ្សេងទៀត។ យើងកាន់តែគិតពីវា នោះយើងកាន់តែចង់បានវា។ ប្រសិនបើយើងគិតពីវារៀងយូរបន្តិច នោះយើងប្រហែលជានឹងបើកឡានពីបីម៉ោងដើម្បីទៅទិញវា បន្ទាប់មកគ្រាន់តែសោកស្តាយថាយើងបានខ្ជះខ្ជាយពេលវេលានិងថវិកា ដើម្បីញុាំរបស់ដែលយើងចង់ញុាំ។

បើនរណាម្នាក់ធ្វើខុសចំពោះយើង ហើយយើងគិតហើយគិតទៀតពីអ្វីដែលគេបានធ្វើឱ្យយើងឈឺចាប់ នោះខ្លួនយើងអាចមានអារម្មណ៏ថាខឹង ហើយដួងចិត្តយើងក៏តានតឹងដែរ។ ការគិតរបស់យើងប៉ះពាល់ដល់ដួងចិត្តយើង ហើយបង្កើតបានជាពាក្យដែលយើងនិយាយ។

ពេលក្រោយទៀត អ្នកឃើញថាខ្លួនអ្នកមិនសប្បាយចិត្ត ឬក្រៀមក្រំ ចូរសួរខ្លួនអ្នកថាតើអ្នកបានគិតអំពីអ្វី? នោះអ្នកនឹងឃើញ ពីទំនាក់ទំនងរវាងការគិត និង អា

រម្មណ៍របស់អ្នក ។

គំនិតគឺជាសមរភូមិ ដែលយើងតយុទ្ធសង្គ្រាមរបស់យើងជាមួយមាសាតាំង ។ ២កូរិនថូស១០:៤-៥ បានបង្រៀនយើងថាយើងកៀរប្រមូលចិត្តគំនិតឱ្យមកស្តាប់បង្គាប់ព្រះគ្រិស្តវិញ ។គឺមានន័យថាយើងគួរតែគិតដោយពឹងផ្អែកទៅព្រះបន្ទូលព្រះជាម្ចាស់ ។ គ្រប់អ្វីៗ ដែលមិនស្របទៅនឹងការបង្រៀនរបស់ព្រះគ្រិស្ត គួរតែកុំទុកនៅក្នុងគំនិតរបស់យើង ហើយបដិសេធន៍ដូចជាសេចក្តីកំភូតដែលមកពីអារក្សវិញ ។ ប្រសិនបើខ្មាំងសត្រូវរបស់អ្នក( មាសាតាំង) អាចគ្រប់គ្រងគំនិតរបស់អ្នកបាន នោះវាក៏អាចគ្រប់គ្រងជីវិតរបស់អ្នកនិងវាសនារបស់អ្នកបានដែរ ។

ឧទាហរណ៍ថា បើអ្នកគិតចង់សំឡាប់ខ្លួន ការនោះគឺមិនមែនមកពីព្រះជាម្ចាស់ទុកនៅក្នុងគំនិតរបស់អ្នកទេ ។ ព្រះទ្រង់ចង់ឱ្យអ្នករស់នៅដោយមានសេចក្តីអំណរនៅជីវិតរបស់អ្នក ។ប្រសិនបើអ្នកគិតថាអ្នកមិនល្អទេ គ្មាននរណាស្រឡាញ់អ្នក ការគិតទាំងនេះមិនមែនមកពីព្រះទេ ពីព្រោះវាមិនស្របទៅនឹងព្រះបន្ទូលរបស់ព្រះអង្គ ។

## ការគិតអវិជ្ជមាន

ចូរប្រុងប្រយ័ត្នចំពោះការគិតទាំងឡាយណាដែលជាគំនិតអវិជ្ជមាន ។ គ្មានការអ្វីនិងគំរោងផែនការណាមកពីព្រះដែលអវិជ្ជមាននោះទេ ។ វាជាការប្រសើរជាងក្នុងការសំឡឹងមើលទឹកកន្លះកែវពេញជាជាងទឹកកន្លះកែវទទេ ។ ធ្វើជាមនុស្សវិជ្ជមាននឹងមិនដែលធ្វើឱ្យអ្នកណាម្នាក់ឈឺចាប់នោះទេ ។

មិនថាជីវិតរបស់អ្នកធ្លាប់មានបញ្ហាអ្វីពីមុនទេ អ្នកត្រូវតែមានទស្សនះវិជ្ជមានសំរាប់អនាគតរបស់អ្នក ។ សូមចូលឱ្យស្របទៅនឹងកិច្ចព្រមព្រៀងជាមួយព្រះជាម្ចាស់

ហើយជឿថាការល្អនឹងកើតឡើងចំពោះអ្នក។ បើអ្នកធ្លាប់ជាមនុស្សអវិជ្ជមានដូចជាខ្ញុំកាលពីមុនដែរ ការគិតវិជ្ជមាននឹងចំណាយពេលដើម្បីធ្វើការហ្វឹកហាត់។ ខ្ញុំធ្លាប់នៅក្នុងបរិស្ថានអវិជ្ជមានយ៉ាងជ្រៅ ហើយតែងតែមានបញ្ហា ឬមានជំងឺ តែបន្ទាប់មកខ្ញុំបានដឹងថា បញ្ហារបស់យើងអាចមកដល់យើងតាមរយៈការគិតអវិជ្ជមាននោះឯង។

នៅក្នុងគម្ពីរសុភាសិត១៥:១៥ ចំពោះមនុស្សកំសត់ទុគិត ថ្ងៃណាក៏ជាថ្ងៃអាក្រក់ដែរ(ដោយការគិតខ្វល់ខ្វាយ និង ការគិតប្រថ្លុលអាក្រក់) រីឯមនុស្សសប្បាយចិត្ត ថ្ងៃណាក៏ជាថ្ងៃបុណ្យដែរ(មិនគិតគ្រប់កាលៈទេសៈ)។

ជាលើកទីមួយព្រះវិញ្ញាណបរិសុទ្ធបានបង្ហាញខគម្ពីរនេះដល់ខ្ញុំ ខ្ញុំអត់បានដឹងថាអ្វីជា "ប្រថ្លុលអាក្រក់"ទេ តែខ្ញុំធ្លាប់រៀនបានថាវាជាការគិតអវិជ្ជមាន និងការគិតគួរឱ្យភ័យខ្លាចដែលថានឹងមានការអាក្រក់ណាមួយនឹងកើតឡើង។ ដូច្នេះខ្ញុំមានតែទទួលយកបញ្ហាដែលខ្ញុំបានមានប្រថ្លុលនោះស្ទើរតែរាល់ដង។ ខ្ញុំចង់ឱ្យជីវិតរបស់ខ្ញុំមានការផ្លាស់ប្តូរ ហើយខ្ញុំមិនយល់ថាហេតុអ្វីបានជាព្រះមិនផ្លាស់ប្តូរសោះ ប៉ុន្តែនៅទីបំផុតទើបខ្ញុំដឹងថា ខ្ញុំត្រូវតែប្តូរការគិតរបស់ខ្ញុំមុនពេលទ្រង់ផ្លាស់ប្តូរជីវិតរបស់ខ្ញុំ។

សូមកុំគិតអវិជ្ជមានលើអ្វីណាមួយឱ្យសោះ... សូម្បីតែអនាគតកាលរបស់អ្នក ឬអតីតកាលរបស់អ្នកក្តី។ ប្រសិនបើអ្នកទុកចិត្តដល់ព្រះជាម្ចាស់ អតីតកាលរបស់អ្នកអាចស្ថិតនៅក្នុងគំរោងផែនការរបស់ព្រះជាម្ចាស់។ គ្រប់កំហុសដែលអ្នកបានធ្វើខុសអាចធ្វើឱ្យអ្នកប្រសើរឡើង និងជាមនុស្សដែលពូកែ។ អ្នកអាចរៀនបានពីកំហុសនោះអញ្ជឹងពេលក្រោយអ្នកនឹងមិនធ្វើខុសម្តងទៀតទេ។ សូមកុំគិតអវិជ្ជមានជាមួយថវិការបស់អ្នក,មិត្តភ័ក្រ្ត,គ្រួសារ,ដូចអ្វីដែលអ្នកឃើញ,មានការងារធ្វើឬអត់មានការងារធ្វើ

កន្លែងដែលអ្នករស់នៅ,ប្រភេទយានជំនិះដែលអ្នកប្រើ ឬ អ្វីផ្សេងៗទៀត។ សូមអភិវឌ្ឍអាកប្បកិរិយាវិជ្ជមាន ហើយវានឹងជួយអ្នកឱ្យវិជ្ជមាននិងមានជីវិតពេញបរិបូរ។

## កុំបារម្ភ ឬ ខ្វល់ខ្វាយ

ការបារម្ភ ឬ ខ្វល់ខ្វាយគឺជាទំរង់ពីរនៃការគិតដែលមិនល្អ។ ការបារម្ភគឺមិនល្អនោះឡើយ ប៉ុន្តែវាអាចបង្កបញ្ហាជាច្រើន។ ចូរផ្ទេរអស់ទាំងការបារម្ភរបស់អ្នកទៅឯព្រះអង្គដោយទុកចិត្តថា ទ្រង់នឹងជួយដោះស្រាយបញ្ហានោះ។ ការបារម្ភធ្វើឱ្យអ្នកចាស់ទៅៗ ហើយធ្វើឱ្យអ្នកឈឺក្បាល ឈឺក្រពះ និង ធ្វើឱ្យអ្នកពិបាកចិត្តទៀត។ វាមិនមែនជាព្រះហឫទ័យរបស់ព្រះសំរាប់ជីវិតរបស់អ្នកឡើយ។

ប្រហែលជាមិនមែនមានតែការបារម្ភតែមួយទេដែលពិបាក ពីព្រោះអ្នកធ្លាប់តែមើលការខុសត្រូវលើខ្លួនអ្នកផ្ទាល់ ហើយគិតគូរថាតើអ្នកគួរធ្វើអ្វីបន្តទៀត ប៉ុន្តែត្រូវចងចាំថា ឥឡូវនេះអ្នកកំពុងរៀនពីរបៀបរស់នៅបែបថ្មីសំរាប់ជីវិតរបស់អ្នក។

មនុស្សដែលមិនមានទំនាក់ទំនងជាមួយព្រះជាម្ចាស់គេមានអារម្មណ៍ហាក់ដូចជាមានទុក្ខកង្វល់ ប៉ុន្តែសំរាប់អ្នកមិនត្រូវមានអារម្មណ៍បែបនេះទេ។ ព្រះជាម្ចាស់គង់នៅខាងអ្នក ហើយទ្រង់មានបន្ទូលថាចូរផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅព្រះជាម្ចាស់ត្បិតទ្រង់តែងតែយកព្រះទ័យទុកដាក់នឹងអ្នករាល់គ្នា(១ពេត្រុស ៥:៧)។

ចំណែកឯការខ្វល់ខ្វាយវិញមានន័យថា យើងកំពុងតែចំណាយពេលវេលាក្នុងថ្ងៃនេះ បារម្ភពីថ្ងៃស្អែក។ ព្រះយេស៊ូបានមានបន្ទូលក្នុងគម្ពីរម៉ាថាយ៦:៣៤ថា ដូច្នេះ កុំឱ្យខ្វល់ខ្វាយពីថ្ងៃស្អែកឡើយ ពីព្រោះថ្ងៃស្អែកនឹងខ្វល់ខ្វាយចំពោះការរបស់ថ្ងៃនោះឯងសេចក្តីលំបាកនៅថ្ងៃណា នោះគឺល្មមត្រឹមថ្ងៃនោះហើយ។ អ្នកនឹងដឹងថាអ្នកត្រូវធ្វើអ្វី

នៅពេលការនោះវាមកដល់។ ពេលវេលាមកដល់ អ្នកនឹងដឹងនូវអ្វីដែលត្រូវធ្វើ តែប្រហែលជាអ្នកមិនដឹលទេទាល់តែការនោះមកដល់សិន ។ព្រះចង់ឱ្យយើងរៀនទុកចិត្តដល់ទ្រង់។ ព្រះអង្គទ្រង់មិនដែលយឺត ហើយទ្រង់ក៏មិនដែលមុនពេលដែរ។ សំរាប់អ្នកជឿថ្មី ជាធម្មតាការរងចាំនេះពិតជាលំបាក ពីព្រោះអ្នកមិនធ្លាប់ជួបការនេះ។ ទោះជាយ៉ាងណាក៏ដោយតែមួយរយៈពេលក្រោយអ្នកនឹងចាប់ផ្តើមស្រឡាញ់វា។ គំនិតរបស់អ្នកអាចនឹងមិនឡើយហត់ទៀតឡើយ ហើយអ្នកនឹងរស់នៅដោយគ្មានការខ្វល់ខ្វាយពីអ្វីនៅថ្ងៃខាងមុខទៀតទេ។

រាល់ពេលអ្នកជួបការល្បួងឱ្យខ្វល់ខ្វាយ ចូររំលឹកដល់វិញ្ញាណអាក្រក់ថា អ្នកគឺជាកូនរបស់ព្រះ ហើយ ទ្រង់បានសន្យាយកចិត្តទុកដាក់មើលថែរក្សាអ្នក។

វិធីដ៏ល្អមួយក្នុងការផ្លាស់ប្រែគំនិតអ្នកជាថ្មីគឺត្រូវបានគេរកឃើញតាមការរៀននិងតាមការសញ្ជឹងគិតទៅលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។វាគឺជាផ្លូវមួយដែលយើងរៀនស្វែងយល់ពីភាពខុសប្លែកគ្នារវាងកាគិតខុសនិងត្រូវ។ ឧទាហរណ៍ មនុស្សម្នាក់គិតថាគេប្រហែលក្រពេញមួយជីវិតរបស់គេ ពីព្រោះភាពក្រខ្សត់តែងតែមាននៅក្នុងគ្រួសាររបស់គេ ប៉ុន្តែអ្នកនឹងឃើញនៅក្នុងព្រះបន្ទូលព្រះដែលថាការនេះមិនមែនជាការពិតទេ។ តាមការជួយពីព្រះជាម្ចាស់ និងតាមការដាក់ចុះនូវផែនការរបស់ទ្រង់សំរាប់ថវិកានៃជីវិតរបស់អ្នក អ្នកអាចបំបែករង្វង់នៃភាពក្រខ្សត់ ហើយអ្នកនឹងមានអ្វីៗគ្រប់គ្រាន់ទៅតាមសេចក្តីត្រូវការក្នុងជីវិតរបស់អ្នក។ ព្រះបន្ទូលព្រះចែងនៅក្នុងគម្ពីរ៣យ៉ូហាន ២ ថា: "អ្នកស្ងួនភ្ងាអើយខ្ញុំប្រាថ្នាចង់ឱ្យអ្នកបានចំរើនឡើងគ្រប់ជំពូក ហើយឱ្យបានសុខសប្បាយ ខាងរូបសាច់ ដូចជាព្រលឹងអ្នកបានចំរើនឡើងដែរ"។ ការស្តាប់តាមដំបូន្មាន

ហើយ ដើរតាមផ្លូវសុចរិតទៀងត្រង់របស់ទ្រង់ នោះទ្រង់នឹងប្រទាននូវអ្វីៗដល់អ្នក។

ព្រះទ្រង់នឹងបំពេញសេចក្ដីត្រូវការរបស់អ្នក ហើយអ្នកមិនចាំបាច់រស់នៅក្នុងភាពភ័យខ្លាចទៀតទេ។ បើអ្នកត្រូវការការងារធ្វើ អ្នកអាចអធិស្ឋានសុំទ្រង់ នោះទ្រង់នឹងជួយអ្នកក្នុងការរកការងារធ្វើ។ ព្រះអង្គទ្រង់នឹងប្រទានពរឱ្យអ្នកមានជ័យជំនះលើអ្វីៗដែលអ្នកធ្វើ។

ព្រះយេស៊ូចង់ឱ្យអ្នកមានជីវិតដ៏ល្អ។ ព្រះអង្គទ្រង់ចង់ឱ្យអ្នករីករាយនឹងជីវិតដែលទ្រង់បានសុគតដើម្បីអ្នក។ ហើយឱ្យអ្នកមានចំណេះ មានការយល់ដឹង ដឹងខុសត្រូវនិងមានការប្រុងប្រយ័ត្ន។ ការរស់នៅដោយគ្មានចំណេះដឹង មនុស្សត្រូវបណ្ដាសារអញ្ចឹងហើយមនុស្សត្រូវស្វែងរកការនោះ។ ព្រះគម្ពីរ១កូរិនថូស១:៣០ចែងថា ដោយសារព្រះ នោះអ្នករាល់គ្នានៅក្នុងព្រះគ្រិស្តយេស៊ូដែលទ្រង់បានតាំងឡើងទុកជាប្រាជ្ញាដែលមកពីព្រះ ។ចូរសុំទ្រង់ដើម្បីឱ្យប្រាជ្ញាអ្នកបានចំរើនឡើងនិងភ្លឺថ្លាក្នុងគំនិត។ ដូច្នេះអ្នកអាចដើរក្នុងផ្លូវរបស់ទ្រង់បាន។ ក្នុងគម្ពីរសុភាសិត៨:១១ចែងថា "ដ្បិតប្រាជ្ញាប្រសើរជាងត្បូងទទឹមហើយរបស់ទាំងប៉ុន្មានដែលមនុស្សនឹងប្រាថ្នាចង់បាន នោះក៏ប្រៀបផ្ទឹមឱ្យស្មើមិនបានផង"។

សៀវភៅដែលលក់ដាច់ជាងគេរបស់ខ្ញុំគឺសមរភូមិនៃគំនិត។ ខ្ញុំសូមផ្ដល់អនុសាសន៍ឱ្យអ្នកអានសៀវភៅនេះឱ្យបានឆាប់ៗតាមតែអាចធ្វើបាន។ ត្រូវចាំថាការគិតសារជាថ្មីរបស់អ្នកវាប្រហែលដូចជាសមរភូមិមួយរយៈពេល ប៉ុន្តែយើងមិនត្រូវបោះបង់ចោលឡើយ។ អស់អ្នកណាដែលព្យាយាមស្វែងរកព្រះ នោះនឹងទទួលបានរង្វាន់ជាទីគាប់ចិត្តពីព្រះជាម្ចាស់។

# ជំពូក ៦

# របៀបនិយាយបែបថ្មី

ពាក្យសំដីគឺជាប្រអប់សំរាប់ដាក់អំណាច។ វាមានអំណាចធ្វើឱ្យប្រសើរបាន ហើយក៏អាចធ្វើឱ្យវិនាសបានដែរ។ កាលដើមដំបូងឡើយ នៅពេលដេលព្រះបានមានបន្ទូល ទ្រង់បានបង្កើតគ្រប់របស់ទាំងអស់ល្អ ហើយយើងគួរតែធ្វើតាមគំរូរបស់ទ្រង់។

ក្នុងគម្ពីរសុភាសិត១៨:២០-២១ ចែងថា មនុស្សអាចរកអាហារបានដោយសារពាក្យសំដី ហើយអ្វីៗដែលគេនិយាយធ្វើឱ្យគេអាចចិញ្ចឹមជីវិតបាន (មិនថាល្អឬអាក្រក់ទេ)។

ស្លាប់រស់ព្រោះតែសំដី អ្នកណាចូលចិត្តនិយាយ អ្នកនោះត្រូវទទួលផលពីពាក្យសំដីរបស់ខ្លួន (ស្លាប់ ឬ រស់)។

ចូរសិក្សាព្រះបន្ទូលនេះដោយប្រុងប្រយ័ត្ន ដ្បិតព្រះបន្ទូលបានប្រាប់យើងជាច្រើនថា ពាក្យសំដីររបស់យើងមានផលរបស់វា។ ផលខ្លះនាំមកនូវការល្អ និងផលខ្លះមកពីអារក្ស។ នៅពេលដែលយើងបើកមាត់និយាយ យើងត្រូវតែស្គាល់អំណាចនៃពាក្យសំដីរបស់យើង។ ការគិតរបស់យើងនឹងក្លាយជាពាក្យសំដីរបស់យើង ហើយវាជាមូលហេតុមួយ ដែលមារសាតាំងទុកការគិតអវិជ្ជមាននៅក្នុងគំនិតរបស់យើង។ វាដឹងថាបើយើងយកការនោះដាក់នៅក្នុងគំនិតរបស់យើង នោះយើងនឹងនិយាយការនោះចេញមកជាមិនខាន ហើយការនោះនឹងឱ្យឱកាសដល់វាដើម្បីបើកទ្វារធ្វើការអាក្រក់របស់វានៅក្នុងជីវិតរបស់យើង។

# របៀបនិយាយបែបថ្មី

ក្នុងគម្ពីរសុភាសិត២១:២៣ចែងថា អ្នកដែលប្រយ័ត្នពាក្យសំដី តែងតែចៀសផុតពីទោសពៃរ៍។

សេចក្ដីល្បួងដ៏ធំបំផុតនៅក្នុងលោកកិយនេះគឺ ការនិយាយអំពីអ្វីដែលយើងមើលឃើញហើយមានអារម្មណ៍ តែព្រះចង់ឱ្យយើងនិយាយពីអ្វីដែលព្រះបន្ទូលទ្រង់បានមានបន្ទូលដែលយើងអាចមាននោះ។ ខ្ញុំមិនសំណូមពរឱ្យអ្នកព្រងើយនឹងកាលៈទេសៈរបស់អ្នកទេ តែខ្ញុំចង់និយាយយ៉ាងណាឱ្យអ្នកយកឈ្នះលើពួកវា ហើយពីរបៀបដែលអ្នកនិយាយ នៅពេលអ្នកមានបញ្ហាច្រើនក្នុងការងារធ្វើជាមួយវា។

ពួកជនជាតិអ៊ីស្រាអែលបានចំណាយពេល៤០ឆ្នាំនៅក្នុងទីរហោស្ថាន ដើម្បីធ្វើដំណើរតែ១១ថ្ងៃ។ ពួកគេបានធ្វើដំណើរជុំវិញភ្នំម្ដងហើយម្ដងទៀត នៅតែចេញមិនផុត។ ពួកគេជួបបញ្ហាជាច្រើន ហើយបញ្ហាដ៏ធំរបស់គេមួយគឺ ការរអ៊ូរទាំ។ ពួកគេរអ៊ូរទាំ និងតវ៉ារាល់ពេលដែលការអ្វីមួយមិនស្របតាមចិត្តរបស់ពួកគេ។ ព្រះចង់ឱ្យយើងសរសើរទ្រង់ ហើយអរព្រះគុណទ្រង់នៅពេលដែលយើងកំពុងស្ថិតនៅក្នុងទីរហោស្ថាននៃជីវិតរបស់យើង ក៏ដូចជានៅតែដើរជុំវិញកំពូលភ្នំដដែលៗ។ អ្វីដែលយើងនិយាយពេលមានបញ្ហាធ្វើឱ្យយើងធ្លាក់ក្នុងអន្ទាក់។

ការនេះស្ដាប់ទៅហាក់ដូចជាចំឡែកសំរាប់អ្នក ប៉ុន្តែ ពាក្យសំដីរបស់អ្នកមានអំណាច។ក្នុងព្រះគម្ពីររ៉ូម៤:១៧ចែងថា យើងបំរើព្រះដែលបានត្រាស់ហៅអ្វីៗដែលគ្មានរូបរាងឱ្យកើតមាន។ ព្រះអង្គទ្រង់ជ្រាបនូវអ្វីដែលទ្រង់ចង់ឱ្យកើតឡើង ហើយទ្រង់មានបន្ទូលពីវាតាមដែលវាបានកើតមាន។ ដើម្បីធ្វើការនេះបាន អ្នកត្រូវតែមើលតាមភ្នែកនៃសេចក្ដីជំនឿ ។សេចក្ដីជំនឿដឹងការពិតនូវអ្វីដែលមិនអាចមើលឬមានអារម្មណ៍

ដែលមានតាំងពីកំណើតមក។ សេចក្តីជំនឿ ធ្វើឱ្យសេចក្តីសន្យារបស់ព្រះបានសំរេច ហើយប្រព្រឹត្តតាមសេចក្តីពិត!

ប្រសិនបើយើងមានបញ្ហា ហើយយើងពិតជាជឿថាព្រះនឹងជួយដោះយើងឱ្យរួច នោះយើងអាចមានអំណរឥឡូវនេះ។ យើងមិនចាំបាច់រងចាំមើលទាល់តែឃើញមានការផ្លាស់ប្តូរនោះទេ ពីព្រោះយើងទទួលបានវាដោយសេចក្តីជំនឿ។ យើងដឹងជ្រៅរាក់ផ្នែកខាងក្នុងដែលកំពុងធ្វើការជំនួសយើង។

នៅក្នុងគម្ពីរអេសេគាល៣៧ ពេលលោកហោរាអេសេគាលសំឡឹងមើលជុំវិញខ្លួន, អ្វីដែលគាត់បានឃើញគឺសុទ្ធតែឆ្អឹងខ្មោចពាសពេញ ហើយសុទ្ធតែស្ងួតហួតហែងទាំងអស់ ហើយព្រះអម្ចាស់បានមានបន្ទូលទៅលោកថា "តើឆ្អឹងទាំងនេះអាចរស់មកជាមនុស្សវិញបានឬទេ" លោកទូលតបថា "បពិត្រព្រះជាម្ចាស់ មានតែព្រះអង្គមួយទេដែលជ្រាប" ព្រះអង្គបានមានបន្ទូលឱ្យលោកអេសេគាលថ្លែងប្រាប់ឆ្អឹងទាំងនេះឱ្យស្តាប់ព្រះបន្ទូលព្រះអម្ចាស់! ហើយលោកក៏ថ្លែងព្រះបន្ទូលតាមបញ្ជារបស់ព្រះ ហើយពេលកំពុងនិយាយស្រាប់តែមានឮសំឡេងឆ្អឹងទាំងនោះកំរើក ចូលជិតគ្នាទៅវិញទៅមក។ ពួកគេក៏មានជីវិត ហើយក្រោកឈរឡើង។ នេះគឺជាគំរូដ៏អស្ចារ្យនៃអំណាចចេស្តារបស់ព្រះបន្ទូលព្រះ។

## ចូរថ្លែងព្រះបន្ទូលព្រះចេញទៅឱ្យឮៗ

ខ្ញុំបានបង្រៀនមនុស្សគ្រប់ទីកន្លែងឱ្យថ្លែងព្រះបន្ទូលឱ្យឮៗ ហើយថ្លែងចេញក្នុងគោលបំណងដែលជាចំណែកនៃការហ្វឹកហ្វឺនខាងព្រលឹងវិញ្ញាណប្រចាំថ្ងៃរបស់ពួកគេ។ នេះគឺជាការបង្រៀនសំខាន់ជាងគេរបស់ព្រះ ហើយខ្ញុំអាចបាននិយាយថា ការនេះបាន

ជួយស្តារផ្នត់គំនិតរបស់ខ្ញុំឡើងវិញ និងធ្វើឱ្យជីវិតរបស់ខ្ញុំប្រសើរឡើង។

ព្រះបន្ទូលរបស់ព្រះជាដាវដ៏មុតស្រួចខាងវិញ្ញាណ និងជាអាវុធដ៏ពិសេសដែលអ្នកត្រូវប្រើដើម្បីតតាំងមារសាតាំង, វាខ្លាចនិងញាប់ញ័រនឹងព្រះបន្ទូលរបស់ព្រះ។ ក្នុងព្រះគម្ពីរលូកា៤យើងឃើញពីការដែលព្រះយេស៊ូត្រូវសាតាំងល្បួង។ ព្រះអង្គទ្រង់បានគង់នៅទីរហោស្ថាន ទ្រង់មិនបានសោយអ្វីជាច្រើនថ្ងៃ ហើយសាតាំងបានដាក់ការគិតនៅក្នុងគំនិតរបស់ទ្រង់។ មារសាតាំងតែងបញ្ឆោតព្រះយេស៊ូ ហើយព្រះយេស៊ូបានមានបន្ទូលតបវិញថា "ដ្បិតមានសេចក្តីចែងទុកមកថា" ទ្រង់ប្រកាសព្រះបន្ទូលចេញទាស់នឹងការបោកបញ្ឆោតនោះៗ។ នៅពេលយើងរៀនតាមគំរូរបស់ព្រះយេស៊ូ នោះយើងនឹងទទួលជ័យជំនះទៅលើអ្វីដែលយើងធ្វើ។

តើអ្នកមានឆន្ទៈក្នុងការចាប់ផ្តើមអធិស្ឋានផ្ចង់អារម្មណ៍ទៅលើអ្វី ដែលអ្នកនឹងនិយាយដែរឬទេ? ប្រសិនបើអ្នកមាឆន្ទៈក្នុងការ ចាប់ផ្តើមផ្ចង់អារម្មណ៍ទៅលើអ្វីដែលអ្នកនិយាយ នោះអ្នកនឹងឃើញនូវអ្វីទាំងនោះដែលអ្នកនិយាយជាច្រើននឹងមិនកើតឡើង នៅក្នុងជីវិតរបស់អ្នកទេ។ ខ្ញុំជឿថា យើងអាចបង្កើន ឬ បន្ថយកំរិតនៃសេចក្តីសុខសាន្ត និងអំណររបស់យើងតាមរយៈការនិយាយរបស់យើង។ បើខ្ញុំកែតម្រូវថា តើហេតុអ្វីបានជាមិននិយាយអ្វីដែលធ្វើឱ្យអ្នករីករាយជំនួសទុក្ខព្រួយវិញ?

ការនិយាយដោយជំនឿគឺជាផ្នែកមួយថ្មីនៃជីវិតរបស់អ្នក ដូច្នេះចូរចាប់ផ្តើមឥឡូវនេះ។ អ្នកអាចនិយាយដូចខាងក្រោមនេះ:

ព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ ហើយទ្រង់មានគំរោងផែនការល្អសំរាប់ជីវិតរបស់ខ្ញុំ។

ខ្ញុំពេញចិត្តគ្រប់ទីកន្លែងដែលខ្ញុំទៅ។

## របៀបរស់នៅបែបថ្មី

អ្វីៗទាំងអស់ដែលខ្ញុំដាក់ដៃគឺមានការរីកចំរើននិងមានជោគជ័យ ។

ព្រះបានបើកផ្លូវដែលត្រឹមត្រូវ ហើយបិទផ្លូវដែលមិនត្រឹមត្រូវដល់ខ្ញុំ ។

ខ្ញុំដើរដោយមានគតិបណ្ឌិត ។

ខ្ញុំពេញដោយសេចក្ដីសុខសាន្ត ។

ខ្ញុំពេញដោយសេចក្ដីអំណរ ។

ខ្ញុំដើរដោយមានសេចក្ដីស្រឡាញ់ ។

មានការល្អជាច្រើននឹងកើតឡើងចំពោះខ្ញុំនៅថ្ងៃនេះ ។

កូនៗរបស់ខ្ញុំទាំងអស់មានស្រឡាញ់និងបំរើព្រះ ។

អាពាហ៍ពិពាហ៍របស់ខ្ញុំកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។

ខ្ញុំមានពរគ្រប់កន្លែងទាំងអស់ដែលខ្ញុំទៅ ។

នៅក្នុងបញ្ជីនិយាយខាងលើពិតជាគ្មានទីបញ្ចប់ ។ សូមឱ្យប្រាកដច្បាស់ថាអ្វីដែលអ្នកនិយាយគឺជាព្រះបន្ទូលរបស់ព្រះដែលទ្រង់មានព្រះបន្ទូល ។ ចូរព្រមព្រៀងនឹងព្រះជាម្ចាស់ នោះទ្រង់នឹងឱ្យលោកកិយទាំងមូលដល់អ្នក ។ នេះនឹងដាក់ផែនការរបស់ព្រះក្នុងសកម្មភាព ហើយវិញ្ញាណអាក្រក់មិនអាចបញ្ឈប់ដល់ការនោះបានឡើយ ។

# ជំពូក ៧

# របៀបនៃការមើលមកកាន់ខ្លួនឯងបែបថ្មី

តើអ្នកមើលមកកាន់ខ្លួនឯងផ្ទាល់យ៉ាងដូចម្ដេច? រូបខ្លួនរបស់អ្នកប្រៀប ដូចជារូបថតដែលអ្នកស្ពាយជាប់ក្នុងកាបូបនៃដួងចិត្តរបស់អ្នក។ ខ្ញុំបានធ្វើការជាមួយមនុស្សដែលមិនចូលចិត្តខ្លួនឯងទាល់តែសោះអស់ជាច្រើនឆ្នាំ។ ខ្ញុំក៏ធ្លាប់មានទំនាក់ទំនងមិនល្អជាមួយនឹងខ្លួនខ្ញុំអស់ជាច្រើនឆ្នាំដែរ ហើយវាបានបំពុលការជាច្រើននៅក្នុងជីវិតរបស់ខ្ញុំ។ ព្រះឡាញ់អ្នក ហើយទ្រង់ចង់ឱ្យអ្នកស្រឡាញ់ខ្លួនអ្នកដែរ។ មិនមែនអាត្មានិយម ឬធ្វើខ្លួនជាផ្លូវកណ្ដាលនោះទេ ប៉ុន្តែស្ថិតក្នុងរបៀបដែលសន្តិភាព។ អ្នកមិនអាចឱ្យអ្វីដែលអ្នកគ្មានទៅអ្នកដទៃបានទេ។ ព្រះទ្រង់ស្រឡាញ់យើងហើយទ្រង់ចង់ឱ្យសេចក្ដីស្រឡាញ់នោះព្យាបាលយើងឱ្យជាជាមុនសិនទើបដល់វេនអ្នកដទៃទៀត។ បើយើងបដិសេធមិនទទួលសេចក្ដីស្រឡាញ់ ដែលព្រះបានឱ្យយើងស្រឡាញ់ខ្លួនយើងទេ នោះយើងពិតជាមិនអាចស្រឡាញ់អ្នកផ្សេងទៀតបានដែរ។

តើគំនិតនៃខ្លួនរបស់អ្នកផ្អែកទៅលើការសម្ដែងរបស់អ្នក? សំរាប់ពួកយើង ភាគច្រើនគឺក្នុងការណីនោះឯង ហើយផ្នត់គំនិតរបស់យើងមិនអាចគិតល្អបានទេ ពីព្រោះការសំដែងរបស់យើងមិនច្បាស់ល្អ។ យើងទាំងអស់គ្នាមិនមែន ជាមនុស្សគ្រប់លក្ខណ៍នោះទេ ហើយយើងក៏តែងតែធ្វើខុសដែរ។ យើងចង់ធ្វើអ្វីដែលត្រឹមត្រូវ ប៉ុន្តែជានិច្ចជាកាល វាហាក់ដូចជារញ៉េរញ៉ៃមិនច្បាស់លាស់។ នោះហើយគឺជាមូលហេតុដែលយើងត្រូវការព្រះយេស៊ូ។ព្រះទ្រង់បង្ហាញកំឡាំងដ៏អស្ចារ្យបំពេញភាពកំសោយរបស់យើង។

# របៀបរស់នៅបែបថ្មី

អ្នកមិនមានអ្វីភ្ញាក់ផ្អើលចំពោះព្រះអង្គឡើយ ។ ព្រះទ្រង់ជ្រាបថា អ្នកដូចអ្វីនៅពេលព្រះទ្រង់ឱ្យអ្នកមានទំនាក់ទំនងជាមួយទ្រង់ផ្ទាល់ ។ព្រះទ្រង់បានជ្រាបគ្រប់កំហុសឆ្គងដែលយើងបានប្រព្រឹត្តនៅក្នុងជីវិត តែទ្រង់នៅតែស្រឡាញ់និងចង់បានយើង ។សូមកុំតឹងតែងចំពោះខ្លួនឯងពេក ។ ចូររៀនទទួលសេចក្ដីមេត្តាករុណារបស់ព្រះសំរាប់ជីវិតប្រចាំថ្ងៃ ។ ចូរក្រោកឡើងរាល់ថ្ងៃធ្វើកិច្ចការដើម្បីថ្វាយសិរីល្អដល់ព្រះឱ្យអស់ពីចិត្តរបស់អ្នកតាមតែអ្នកអាចធ្វើបាន ។ ចូរធ្វើឱ្យអស់ពីចិត្តរបស់អ្នក ពីព្រោះអ្នកស្រឡាញ់ព្រះអង្គ មិនមែនឱ្យតែព្រះអង្គស្រឡាញ់អ្នកតែម្ខាងនោះទេ ។ ព្រះទ្រង់ស្រឡាញ់អ្នកយ៉ាងខ្លាំង ហើយសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះអ្នកគឺឥតខ្ចោះ ។ រៀងរាល់ពេលយប់ ចូរសុំព្រះឱ្យអត់ទោសរាល់អំពើបាបនិងកំហុសឆ្គងរបស់អ្នក ដើម្បីឱ្យយើងអាចគេងទៅលក់ស្រួល និងដើម្បីចាប់ផ្ដើមថ្ងៃថ្មីទៀត ។

មារសាតាំងប្រឆាំងទាស់នឹងអ្នក តែព្រះជាម្ចាស់គង់នៅខាងអ្នក ។ អ្នកត្រូវតែនៅខាងព្រះអង្គ ពីព្រោះនៅពេលគ្នាពីរនាក់ព្រមព្រៀងគ្នា នោះពួកគេរឹតតែមានកម្លាំងខ្លាំងថែមទៀត ។ អ្នកជាមនុស្សពិសេសនៅចំពោះព្រះនេត្រព្រះ ហើយអ្នកមានទេពកោសល្យដ៏ល្អជាច្រើនដែលមានប្រយោជន៍សំរាប់ព្រះជាម្ចាស់ ។ សូមកុំគ្រាន់តែមើលគ្រប់អ្វីដែលអ្នកគិតនោះថាខុសឆ្គងចំពោះអ្នក ហើយក៏កុំឱ្យមើលថា តើចំងាយប៉ុន្មានដែលត្រូវទៅ ឬមើលថាតើចំងាយប៉ុន្មានដែលអ្នកត្រូវមកដែរ ឥឡូវនេះអ្នកគឺជាអ្នកដែលជឿលើព្រះយេស៊ូគ្រិស្ដ នោះគឺជាការចាប់ផ្ដើមនូវគ្រប់អ្វីដែលអស្ចារ្យក្នុងជីវិតរបស់អ្នក ។

# របៀបនៃការមើលមកកាន់ខ្លួនឯងបែបថ្មី

# ការស្គាល់ភាពសុចរិត

ភាពសុចរិត(ការឈរដោយត្រឹមត្រូវជាមួយព្រះ) មកតាមរយៈសេចក្តីជំនឿក្នុងព្រះយេស៊ូគ្រិស្ត មិនមែនមកតាមរយៈការងារផ្ទាល់ខ្លួននោះឡើយ។ វាជាអំណោយរបស់ព្រះជាម្ចាស់ ហើយប្រទានឱ្យនៅពេលដែលអ្នកព្រមទទួល ព្រះយេស៊ូជាព្រះអង្គសង្គ្រោះរបស់អ្នក។

មានខគម្ពីរយោងការនេះជាច្រើន។ ខ្ញុំនឹងនិយាយពីរបីចំណុចសំរាប់ជាការលើកទឹកចិត្តរបស់អ្នកៈ

ក្នុងគម្ពីរ២កូរិនថូស៥:២១"ដ្បិតឯព្រះអង្គដែលមិនបានស្គាល់បាបសោះ(ភាពជាក់ស្តែង)នោះព្រះទ្រង់បានធ្វើឱ្យត្រឡប់ជាតួបាបជំនួសយើងរាល់គ្នាវិញ ដើម្បីឱ្យយើងរាល់គ្នាបានត្រឡប់ទៅជា(អត់ធ្មត់ជាមួយ,ចេះគិតនិងជាគំរូនៃ) សេចក្តីសុចរិតរបស់ព្រះដោយនូវព្រះអង្គនោះឯង(តើយើងគួរធ្វើជាអ្វី, យល់ស្រប និង អាចទទួលបានហើយមានទំនាក់ទំនងដ៏ត្រឹមត្រូវជាមួយទ្រង់ដោយភាពល្អរបស់ទ្រង់។

អូហូ!បទគម្ពីរនេះអស្ចារ្យមែន! ព្រះគ្រិស្តគ្មានបាបទាល់តែសោះ តែដោយព្រោះសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះយើង ទ្រង់បានដករាល់អំពើបាបយើង ដូច្នេះហើយយើងគួរតែមានទំនាក់ទំនងពិសេសជាមួយព្រះវរបិតា។ ឥឡូវនេះ ព្រះទតមើលយើងព្រមព្រៀង និងយល់ស្រប ហើយឱ្យយើងឈរកន្លែងដែលត្រូវជាមួយទ្រង់ ពីព្រោះយើងបានព្រមទទួលព្រះយេស៊ូជាព្រះសង្គ្រោះរបស់យើង។ ខ្ញុំត្រូវតែនិយាយម្តងទៀតថា...អូហូ អស្ចារ្យមែន!

គ្មានមនុស្សណាម្នាក់ សុចរិតនោះឡើយ (ធ្វើឱ្យសុចរិត រួចពីបំណុល និង ភាព

យុត្តិធម៌ដែលអាចទទួលយកបាន) តាមក្រិតវិន័យនៅក្នុងផ្លូវរបស់ព្រះអង្គ។

នៅក្នុងគម្ពីររ៉ូម៣:២០ចែងថា "គ្មាននរណាម្នាក់បានសុចរិត (សុចរិត,មិនជាប់ទោស និងប្រព្រឹត្តតាមវិន័យ)នៅចំពោះព្រះភ័ក្ត្រព្រះអង្គដោយការប្រព្រឹត្តតាមវិន័យនោះទេ ព្រោះ(ការប្រព្រឹត្តច្បាប់តាម)វិន័យគ្រាន់តែ នាំឱ្យគេស្គាល់អំពើបាបប៉ុណ្ណោះ (មិនមែនគ្រាន់តែដឹង តែត្រូវស្គាល់អំពើបាបដែលធ្វើការឆ្ពោះទៅរកការប្រែចិត្ត,សេចក្តីជំនឿ, និងអត្តចរិកស្អាតបរិសុទ្ធ)។

ក្នុងគម្ពីរ រ៉ូម៣:២២ ព្រះជាម្ចាស់ប្រោសអ្នកដែលមានជំនឿលើព្រះយេស៊ូគ្រិស្ត (ព្រះ មេស៊ី)ឱ្យបានសុចរិត(មានន័យថា)គឺព្រះអង្គធ្វើដូច្នេះចំពោះអស់អ្នកដែលជឿ។ មនុស្សទាំងអស់មិនខុសគ្នាត្រង់ណាឡើយ។

គម្ពីរកាឡាទី២:១៦យើងដឹងថា ព្រះជាម្ចាស់ពុំប្រោសមនុស្សឱ្យបានសុចរិតដោយការប្រព្រឹត្តតាមវិន័យទេ គឺបានសុចរិតដោយសារជំនឿលើព្រះយេស៊ូគ្រិស្តវិញ។ ដូច្នេះយើងក៏បានជឿលើព្រះយេស៊ូវិញដែរ ដើម្បីព្រះជាម្ចាស់ប្រោសយើងឱ្យបានសុចរិតតាមរយៈជំនឿលើព្រះយេស៊ូ(មួយគត់) គឺមិនមែនដោយបានប្រព្រឹត្តតាមវិន័យនោះទេ។

គឺជាការសំខាន់ណាស់សំរាប់ការរីកចំរើនខាងព្រលឹងវិញ្ញាណរបស់អ្នក ដែលអ្នកមើលឃើញខ្លួនឯងកំពុងឈរកន្លែងត្រឹមត្រូវនៅចំពោះព្រះតាមរយៈសេចក្តីជំនឿរបស់អ្នកក្នុងព្រះយេស៊ូគ្រិស្ត។ វាគឺជាអំណោយដែលព្រះប្រទានឱ្យ។ បើយើងតែងតែមានអារម្មណ៍មិនល្អចំពោះខ្លួនយើង ទាំងឆ្ងល់ថា ព្រះមិនសព្វព្រះទ័យនឹងខ្លួនយើង នោះយើងនឹងបាត់អំណាចដែលព្រះចង់ឱ្យយើងដើរនោះហើយ។ អ្នកដែលជឿលើព្រះយេស៊ូគ្រិស្ត គឺយើងមានអំណាចចេស្តាលើវិញ្ញាណអាក្រក់ តែយើងត្រូវតែឈរនៅចំពោះ

ភាពសុចរិតរបស់ព្រះ មិនមែនក្នុងការអន់ចិត្ត និងការស្អប់ខ្ពើមខ្លួននោះទេ ។

គម្ពីរអេភេសូរ៦បាននិយាយយ៉ាងច្បាស់ថា យើងយកសេចក្តីសុចរិតធ្វើជាអាវក្រោះការពារដើមទ្រូង ។ ដូចជាទាហានពាក់អាវក្រោះការពារទ្រូងរបស់គាត់ដែរ ។ តើអ្នកជឿអ្វីដោយពិតប្រាកដពីខ្លួនរបស់អ្នក? តើអ្នកអាចជឿដោយជំនឿថា អ្នកឈរយ៉ាងត្រឹមត្រូវជាមួយព្រះទេ? អ្នកអាចធ្វើបាន បើអ្នកនៅតែទុកចិត្តដល់ព្រះនូវអ្វីដែលព្រះយេស៊ូបានធ្វើសំរាប់អ្នក ហើយមិនមែនទៅលើគ្រប់កំហុសដែលអ្នកធ្វើទេ។ អ្នកនឹងប្រព្រឹត្តខុស ហើយពេលអ្នកធ្វើអ្នកត្រូវប្រែចិត្តភ្លាមៗ ដើម្បីទទួលការអត់ទោសពីព្រះជាម្ចាស់ ។ នេះគឺជាផ្លូវតែមួយគត់ដែលយើងអាចដើរក្នុងភាពសុចរិតរបស់ព្រះបាន ។ ក្នុងការដែលយើងដើរនេះ វាមិនមែនជាភាពសុចរិតរបស់យើងទេ ពីព្រោះភាពសុចរិតរបស់យើងគឺដូចជាភាពកខ្វក់ ប៉ុន្តែយើងនៅតែអាច និងគួរតែដើរនៅក្នុងភាពសុចរិតរបស់ព្រះតាមរយៈសេចក្តីជំនឿរបស់យើងក្នុងព្រះយេស៊ូគ្រិស្ត ។

នេះជាអាកប្បកិរិយាដ៏ប្រសើរថ្មី ដែលឥឡូវនេះអ្នកអាចថ្វាយខ្លួនរបស់អ្នកជាចំណែកនៃ "ជីវិតរបស់អ្នក" ក្នុងចំណោមអ្នកជឿក្នុងព្រះយេស៊ូគ្រិស្ត ។

## ការរីករាយនឹងខ្លួនអ្នក

ឥឡូវនេះអ្នកមានសេរីភាពក្នុងការរីករាយជាមួយនឹងខ្លួនអ្នក ហើយការនេះគឺជាព្រះហឫទ័យរបស់ព្រះដែលចង់ឱ្យអ្នកធ្វើ។ សូមកុំពឹងផ្អែកលើទ្រព្យសម្បត្តិរបស់អ្នក និងវាយតំលៃទៅលើអ្វីដែលអ្នកដទៃទៀតនិយាយ ឬ បាននិយាយពីខ្លួនអ្នក។ កុំផ្អែកភាពរីករាយទៅលើរបៀបដែលមនុស្សរាប់អានអ្នក ឬភាពពូកែរបស់អ្នកនៅក្នុងជីវិតអ្នកឡើយ ។ព្រះជាម្ចាស់ទ្រង់គិតថា អ្នកមានតំលៃអស្ចារ្យល្មមក្នុងងការបញ្ជូនព្រះរាជ

បុត្រារបស់ទ្រង់មកសុគតដើម្បីអ្នក ហើយនោះគឺជាហេតុផលដើម្បីអំណរអរ ។

ព្រះគម្ពីរបង្រៀនយើងជាច្រើនថា ព្រះសព្វព្រះទ័យឱ្យយើងរីករាយជាមួយនឹងខ្លួនឯង ហើយវាមិនអាចទៅរួចទេ បើអ្នកមិនរីករាយនឹងខ្លួនឯងនោះ។ អ្នកគឺជាមនុស្សម្នាក់ ដែលអ្នកមិនដែលចេញឆ្ងាយសូម្បីតែមួយនាទី។ បើអ្នកមិនរីករាយនឹងខ្លួនអ្នកទេ អ្នកមិនអាចគ្រប់គ្រងខ្លួនឯងបានឡើយ។

ដូចជារូបខ្ញុំ អ្នកប្រហែលជាខុសពីអ្នកដទៃទៀតដែលអ្នកស្គាល់ ប៉ុន្តែវាមិនថ្វីទេ។ ជាការពិតវាគឺជាការដែលព្រះបានធ្វើដោយមានគោលបំណង។ ព្រះទ្រង់បានបង្កើតយើងទាំងអស់គ្នាខុសគ្នាបន្តិចៗ។ ព្រះទ្រង់មានវិធីខុសៗគ្នា។ អ្នកមិនខុសប្លែកពីគេទេ អ្នកមានប្រភពដើមតែមួយគត់ ហើយមានតំលៃជាងអ្វីៗទាំងអស់។

កុំប្រៀបធៀបខ្លួនអ្នកជាមួយអ្នកដទៃ ហើយចំណាយជីវិតរបស់អ្នកទៅប្រកួតប្រជែងជាមួយគេ(២កូរិនថូស១០:១២)។ ចូរធ្វើខ្លួនជាខ្លួនអ្នកចុះ ហើយរីករាយតាមរបៀបរបស់អ្នក អ្នកត្រូវការផ្លាស់ប្តូរខាងក្នុង ដូចយើងដែរ ហើយព្រះវិញ្ញាណបរិសុទ្ធនឹងរវល់ជាមួយនឹងជីវិតរបស់អ្នកក្នុងការធ្វើការផ្លាស់ប្តូរក្នុងអ្នករហូត។ ដំណឹងល្អគឺថាខ្លួនអ្នកមានសេរីភាពក្នុងការរីករាយនឹងខ្លួនឯងក្នុងខណៈការងារកំពុងដំណើរការ។

# ជំពូក ៨

## ការផ្លាស់ប្តូរពីភាពភ័យខ្លាចមកកាន់សេចក្តីជំនឿ

យើងដឹងហើយថាអារម្មណ៍នៃភាពភ័យខ្លាចដូចម្តេច។ វាគឺជាការធ្វើទារុណកម្ម ហើយបង្អាក់ភាពលូតលាស់របស់យើង ។ភាពភ័យខ្លាចអាចធ្វើឱ្យយើងញ័រ,បែកញើស, មានអារម្មណ៍ចុះខ្សោយ និងធ្វើឱ្យយើងរត់ចោលនូវអ្វីដែលយើងគួរប្រឈមមុខ។

ភាពភ័យខ្លាចមិនមែនមកពីព្រះទេ។ វាជាឧបករណ៍របស់មារសាតាំងដើម្បីរារាំង យើងមិនឱ្យមានជីវិតរស់នៅបានប្រសើរដែលព្រះចង់ឱ្យយើងមាន(២ធីម៉ូថេ១:៧)។ ព្រះជាម្ចាស់ទ្រង់ចង់ឱ្យយើងរស់នៅក្នុងសេចក្តីជំនឿ។ សេចក្តីជំនឿគឺជាការពឹងផ្អែក ផ្ទាល់ខ្លួនរបស់យើងទាំងស្រុងទៅលើព្រះជាម្ចាស់ ដោយការទុកចិត្តនិងមានទំនុកចិត្ត លើព្រះចេស្តាព្រះជាម្ចាស់,ប្រាជ្ញា,និងភាពបរិសុទ្ធរបស់ទ្រង់ដោយអស់ពីចិត្ត។ ការនេះ គឺជាភ័ស្តុតាងដែលយើងមើលមិនឃើញ និងការជឿជាក់នៃភាពពិតរបស់ពួកគេ។

សេចក្តីជំនឿធ្វើការក្នុងអាណាចក្រនៃវិញ្ញាណ។ អ្នកប្រហែលជាស៊ាំក្នុងការជឿ លើតែអ្វីដែលអាចមើលឃើញនិងមានអារម្មណ៍តែប៉ុណ្ណោះ ប៉ុន្តែក្នុងនាមជាកូនព្រះអ្នក នឹងត្រូវការការរស់នៅដ៏សុខស្រួលក្នុងអាណាចក្រមួយដែល អ្នកមិនអាចមើលឃើញ (អាណាចក្រខាងវិញ្ញាណ)។យើងមើលព្រះមិនឃើញព្រោះទ្រង់ជាវិញ្ញាណ ប៉ុន្តែយើង ជឿយ៉ាងមុតមាំក្នុងទ្រង់។ យើងមិនបានឃើញទេវតាញឹកញាប់ ប៉ុន្តែព្រះបន្ទូលទ្រង់ បានថែងថា ពួកគេទាំងអស់នៅជុំវិញខ្លួនយើងដើម្បីការពារយើង។ ដោយការបង្ហាញ ពីសេចក្តីជំនឿរបស់យើងក្នុងព្រះនិងព្រះបន្ទូលទ្រង់ នោះយើងអាចចូលទៅក្នុងអាណា

ចក្រនៃវិញ្ញាណបាន ហើយទាញយកនូវអ្វីដែលព្រះចង់ឱ្យយើងមានអំណរ ប៉ុន្តែវាមិនទាន់ពិតនៅឡើយទេ។

មារសាតាំង វាត្រេកអរក្នុងការហៅឱ្យប្រុងប្រយ័ត្នចំពោះកាលៈទេសៈរបស់យើង ហើយវាព្យាយាមធ្វើឱ្យយើងភ័យខ្លាចពីអនាគត។ ម្យ៉ាងវិញទៀត ព្រះទ្រង់សព្វព្រះហឫទ័យឱ្យយើងទុកចិត្តទ្រង់ហើយជឿថាទ្រង់ធំជាងកាលៈទេសៈទាំងនោះ ឬ ធំជាងការគំរាមគំហែងរបស់វិញ្ញាណអាក្រក់ទាំងនោះ។

ក្នុងព្រះគម្ពីរមាននិយាយជាច្រើនពីគំរូយ៉ាងល្អៗរបស់មនុស្សប្រុស និងមនុស្សស្រីដែលឃើញខ្លួនឯងឋិតនៅក្នុងកាលៈទេសៈអស់សង្ឃឹម ហើយជាលទ្ធផលដែលទទួលបានគឺជាភាពភ័យខ្លាចមានពេញនៅក្នុងដួងចិត្ត ។ប៉ុន្តែពួកគេបានសំរេចចិត្តដាក់សេចក្តីជំនឿរបស់គេក្នុងព្រះ ហើយពួកគេបានមានបទពិសោធន៍ខាងការថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ ។អ្នកត្រូវតែសំរេចចិត្តថា អ្នកនឹងរស់នៅក្នុងភាពភ័យខ្លាច ឬក៏រស់នៅក្នុងសេចក្តីជំនឿ។ ទោះបីជាឥឡូវនេះអ្នកជាគ្រិស្តបរិស័ទក៏ដោយ ក៏ជីវិតរបស់អ្នកនៅតែអាចរស់នៅដោយភាពភ័យខ្លាចសព្វបែបយ៉ាងដដែល លុះត្រាតែអ្នកសំរេចចិត្តរស់ដោយសេចក្តីជំនឿវិញ។ អ្នកបានទទួលព្រះយេស៊ូជាព្រះអង្គសង្គ្រោះរបស់អ្នកដោយសេចក្តីជំនឿៈ ជំហ៊ានបន្ទាប់ទៀតគឺ រៀនពីការរស់នៅដោយសេចក្តីជំនឿ។

ដំណឹងល្អនេះ សំដែងឱ្យដឹងថា ព្រះជាម្ចាស់ប្រោសប្រទានឱ្យមនុស្សបានសុចរិតដោយសារជំនឿនិងឱ្យគេកាន់តាមជំនឿ (បង្ហាញតាមរយៈសេចក្តីជំនឿដែលជំរុញឱ្យមានសេចក្តីជំនឿថែមទៀត) ដូចមានចែងទុកមកថាៈ "មនុស្សសុចរិតរស់នៅដោយសារសេចក្តីជំនឿ "។( រ៉ូម១ៈ១៧ )។

ដូចដែលយើងបានយល់ពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយទទួលស្គាល់ថា

# ការផ្លាស់ប្តូរពីភាពភ័យខ្លាចមកកាន់សេចក្តីជំនឿ

យើងបានធ្វើយ៉ាងត្រូវចំពោះព្រះ តាមរយៈការសុគតនិងការរស់ឡើងវិញរបស់ព្រះយេស៊ូ យើងឃើញថាវាងាយស្រួលក្នុងការដើរដោយសេចក្តីជំនឿ។ យើងចាប់ផ្តើមទុកចិត្តព្រះក្នុងការថែរក្សាយើង ប្រសើរជាងអារម្មណ៍យើងត្រូវតែធ្វើដោយខ្លួនឯង។

ភាពក្លាហានមិនមែនជាការអវត្តមាននៃភាពភ័យខ្លាចទេ ប៉ុន្តែវាជាសកម្មភាពដែលត្រូវធ្វើក្នុងវត្តមាននៃភាពភ័យខ្លាចវិញ។ ពេលព្រះទ្រង់បានមានបន្ទូលប្រាប់ពួកបាវបំរើទ្រង់កុំឱ្យខ្លាច ទ្រង់មិនបានបញ្ជាឱ្យពួកគេមិនឱ្យមានអារម្មណ៍ភ័យខ្លាចនោះទេ តែទ្រង់បានប្រាប់ពួកគេឱ្យស្តាប់បង្គាប់ទ្រង់ មិនថាពួកគេបានមានអារម្មណ៍យ៉ាងណាទេ។ ព្រះទ្រង់ជ្រាបថា វិញ្ញាណនៃការភ័យខ្លាចនឹងនៅតែព្យាយាមរំខានការលូតលាស់របស់យើងក្នុងការដើរជាមួយព្រះអង្គ។ ដូច្នេះ ហើយបានជាទ្រង់ប្រាប់យើងនូវព្រះបន្ទូលទ្រង់ម្តងហើយម្តងទៀតថា ព្រះគង់នៅជាមួយយើងគ្រប់ពេលវេលា ហើយដោយព្រោះដូច្នេះហើយ យើងមិនត្រូវចុះចាញ់នឹងភាពភ័យខ្លាចឡើយ។

លោកអេឡេន័រ រូសេវែល Eleanor Roosevelt បាននិយាយថា "អ្នកបង្កើនកម្លាំង, ភាពក្លាហាន, ហើយនិងទំនុកចិត្ត ពីគ្រប់ទាំងបទពិសោធន៏អ្វីមួយដែលអ្នកពិតជាឈប់ផ្ទង់ទៅលើភាពភ័យខ្លាចដែលនៅចំពោះមុខ។ អ្នកត្រូវតែធ្វើអ្វី ដែលអ្នកគិត ថាអ្នកមិនអាចធ្វើបាន "។

នៅក្នុងគម្ពីរទុតិយកថា៣១:៦ចែងថា "ចូមានកម្លាំងនិងចិត្តក្លាហានឡើង! កុំភ័យខ្លាចឬតក់ស្លុតនៅចំពោះមុខពួកគេឱ្យសោះ ដ្បិតព្រះជាម្ចាស់ផ្ទាល់ជាព្រះរបស់អ្នក និងយាងទៅជាមួយអ្នក។ ព្រះអង្គមិនបោះបង់ចោលអ្នកដាច់ខាត!"។

មានតែសេចក្តីជំនឿមួយគត់ដែលធ្វើឱ្យព្រះសព្វព្រះហឫទ័យ។ យើងទទួលពីព្រះជាម្ចាស់តាមសេចក្តីជំនឿ។ ដូច្នេះ ការនេះគឺសំខាន់បំផុតសំរាប់អ្នកជឿព្រះយេស៊ូថ្មី

ដើម្បីរៀនពីសេចក្ដីជំនឿ ហើយចាប់ផ្ដើមដើរក្នុងសេចក្ដីជំនឿដែរ។ ការអភិវឌ្ឍន៍សេចក្ដីជំនឿដ៏រឹងមាំគឺបានធ្វើរួចហើយ គឺដូចជាការពង្រឹងសាច់ដុំឱ្យរឹងមាំដែរ។ អ្នកហ្វឹកហាត់សេចក្ដីជំនឿរបស់អ្នកបន្តិចម្ដងបន្តិចម្ដង ហើយរាល់ពេលអ្នកអនុវត្ត នោះសេចក្ដីជំនឿនឹងរឹងមាំឡើង។

ព្រះគម្ពីរម៉ាថាយ១៧:២០ បានបង្រៀនយើងថា អស់អ្នកដែលជឿនោះអាចធ្វើគ្រប់ការទាំងអស់បាន។ មានជំនឿតែបន្តិចនោះអាចរើភ្នំនៃបញ្ហាចេញពីជីវិតបាន។ ជីវិតរបស់អ្នកប្រហែលជាបានព្យាយាមចំណាយពេលដើម្បីដោះស្រាយ គ្រប់បញ្ហាដែលមាន ហើយជាញយៗអ្នកមានអារម្មណ៍ខឹងនិងខកចិត្ត។ បើដូច្នេះ អ្នកកំពុងតែស្ថិតនៅលើបទពិសោធន៍ថ្មីមួយ។ ឥឡូវនេះអ្នកអាចនិយាយទៅកាន់ព្រះបាន(អធិស្ឋាន) ហើយយាងទ្រង់មកជួយដោះស្រាយបញ្ហាផ្សេងៗ ដែលធ្វើឱ្យអ្នកព្រួយចិត្ត ហើយអ្នកនឹងឃើញថា អ្វីដែលមនុស្សមិនអាចធ្វើបានតែព្រះទ្រង់អាចធ្វើបាន។

យោងតាមសេចក្ដីជំនឿរបស់អ្នក នោះអ្នកនឹងធ្វើវាបាន(ម៉ាថាយ៩:២៩)។ អ្នកប្រហែលជារស់នៅក្នុងភាពភ័យខ្លាចស្ទើរតែជិតមួយជីវិតរបស់អ្នក ប៉ុន្តែឥឡូវនេះ ដល់ពេលដើម្បីផ្លាស់ប្ដូរការភ័យខ្លាចនោះទៅជាសេចក្ដីជំនឿក្នុងព្រះវិញ។ វានឹងចំណាយពេលជាច្រើនដើម្បីរៀនពីរបៀបថ្មី តែសូមកុំបាក់ទឹកចិត្ត និងចុះចាញ់ឡើយ។ គ្រប់អ្វីៗទាំងអស់ដែលនៅលើផែនដីនេះ ដំណើរការគឺពឹងផ្អែកទៅលើច្បាប់នៃការលូតលាស់។ បន្តិចម្ដងៗគ្រប់អ្វីៗទាំងអស់នឹងផ្លាស់ប្ដូរ ប្រសិនបើយើងនៅតែបន្តធ្វើអ្វីដែលព្រះប្រាប់យើងឱ្យធ្វើ។

# ជំពូក ៩

# ជីវិតរីករាយ

ចោរវាមកគិតតែពីលួចប្លន់ គិតតែពីសម្លាប់ និង បំផ្លាញប៉ុណ្ណោះ។ រីឯខ្ញុំវិញ ខ្ញុំមក ដើម្បីឱ្យមនុស្សលោកមានជីវិត ហើយឱ្យគេមានជីវិតពេញបរិបូណ៌(ឱ្យពេញរហូតដល់ហៀរ)។ យ៉ូហាន ១០:១០

ព្រះយេស៊ូបានសុគត ដូច្នេះអ្នកអាចរីករាយក្នុងជីវិតរបស់អ្នកបាន។ ការទាំងនោះមិនមែនមានន័យថា អ្នកនឹងទទួលគ្រប់អ្វីដែលអ្នកចង់បាន ដោយគ្មានការពិបាកនោះទេ។ វាមានន័យថា តាមរយៈទំនាក់ទំនងរបស់អ្នកជាមួយព្រះជាម្ចាស់ អ្នកអាចពុះពារលើទុក្ខលំបាកនៅលើលោកិយនេះបាន។ អ្នកអាចបោះបង់ទុក្ខលំបាកនៅលោកិយនេះបាន និងចែកចាយពីការរស់ឡើងវិញនៃជីវិតដោយសារព្រះជាម្ចាស់ តាមរយៈអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។

ព្រះជាម្ចាស់ជាជីវិតដ៏ពិតប្រាកដរបស់យើង។ ក្នុងទ្រង់ យើងរស់នៅ មានចលនា និងមានជីវិត។ ការរៀនដើម្បីភាពរីករាយនៃជីវិត ព្រះនឹងរំដោះអ្នកឱ្យមានជីវិតរីករាយរាល់ថ្ងៃ។ ចូររីករាយក្នុងការប្រកបជាមួយព្រះជាម្ចាស់។ ព្រះជាម្ចាស់មិនសព្វព្រះទ័យនឹងអ្វីៗដែលធ្វើឱ្យអ្នកខ្វល់ខ្វាយទេហើយព្រះគម្ពីរបានចែងយ៉ាងច្បាស់ថា ព្រះជាម្ចាស់នឹងធ្វើឱ្យអ្វីៗដែលធ្វើឱ្យអ្នកមានការខ្វល់ខ្វាយនោះ។ ព្រះជាម្ចាស់កំពុងធ្វើការក្នុងជីវិតរបស់អ្នករាល់ពេល ហើយនាំអ្នកឱ្យចូលទៅក្នុងបំណងព្រះហឫទ័យរបស់ព្រះអង្គយ៉ាងពេញលេញ។

## របៀបរស់នៅបែបថ្មី

សូមកុំឱ្យខ្លាចព្រះក្នុងផ្លូវខុសឡើយ។ យើងគួរតែមានការគោរពកោតខ្លាចដល់ព្រះវិញ មានន័យថាយើងគួរតែគោរពទ្រង់និងទទួលស្គាល់ថា ទ្រង់មានគ្រប់អស់ទាំងអំណាចចេស្ដា ហើយធ្វើតាមនូវអ្វីដែលទ្រង់មានបន្ទូល។ ប៉ុន្តែយើង មិនគួរខ្លាចព្រះខ្វាល់រាល់ពេលយើងធ្វើខុស ឬ ថាព្រះនឹងដាក់ទោសយើងរាល់ពេលណាយើងខំធ្វើឱ្យបានល្អតែបែរជាបរាជ័យនោះទេ។ ព្រះអង្គពេញដោយសេចក្ដីមេត្តាករុណា ហើយទ្រង់យឺតនឹងខ្ញាល់។ ទ្រង់បានរងទុក្ខយូរណាស់មកហើយ ហើយទ្រង់ស្គាល់កិរិតរបស់យើង និងយល់ពីភាពកំសោយ ហើយនិងគុណវិបត្តិរបស់យើង។

បើសិនអ្នកដូចពួកយើងខ្លះ នោះអ្នកមានកិច្ចការជាច្រើននៅក្នុងជីវិត និងបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនរបស់អ្នកដែលត្រូវផ្លាស់ប្ដូរ ហើយព្រះនឹងផ្លាស់ប្ដូរការនោះ។ ប៉ុន្តែដំណឹងល្អគឺអ្នកអាចរីករាយជាមួយព្រះ និងរីករាយក្នុងជីវិតរបស់អ្នកក្នុងខណៈពេលដែលព្រះអង្គកំពុងធ្វើការផ្លាស់ប្ដូរ។

ជីវិតដែលអ្នកកំពុងតែមានឥឡូវនេះ ប្រហែលជាមិនមែនជាជីវិតមួយដែលអ្នកចង់បញ្ចប់ជាមួយនោះទេ ប៉ុន្តែ គឺជាជីវិតតែមួយគត់ដែលអ្នកមានសព្វថ្ងៃនេះ។ ដូច្នេះអ្នកត្រូវការចាប់ផ្ដើមរីករាយជាមួយវា។ ចូរស្វែងរកអ្វីៗដែលល្អនៅក្នុងជីវិត។ ចូរវិជ្ជមាននិងរៀនមើលការល្អក្នុងអ្វីៗគ្រប់យ៉ាង។ ចូររីករាយជាមួយគ្រួសារនិងមិត្តសំឡាញ់របស់អ្នក។ កុំទុកពួកគេចោល ហើយត្រូវនៅតែព្យាយាមក្នុងការផ្លាស់ប្ដូរពួកគេ។ អធិស្ឋានសំរាប់ពួកគេ ហើយសូមឱ្យព្រះផ្លាស់ប្ដូរពួកគេវិញ។

ចូររីករាយជាមួយការងារ ជាមួយគេហដ្ឋាន និងរីករាយជាមួយជីវិតសាមញ្ញប្រចាំថ្ងៃរបស់អ្នក។ ការទាំងនេះអាចកើតឡើងបានប្រសិនបើអ្នកទុកចិត្តដល់ព្រះ ហើយសំ

រេចចិត្តមានអាកប្បកិរិយាល្អ ។ ចូរឱ្យភ្នែករបស់អ្នកសំឡឹងមើលទៅរកព្រះជាម្ចាស់ ហើយមិនត្រូវឱ្យកំហុសណាមួយមាននៅក្នុងជីវិតរបស់អ្នក ក្នុងគ្រួសាររបស់អ្នក និង នៅក្នុងលោកិយនេះជះឥទ្ធិពលដល់ជីវិតរីករាយនោះឡើយ ។ ព្រះជាម្ចាស់មានគំរោង ការណ៍ដ៏ល្អសំរាប់អ្នក ហើយទ្រង់បានចាប់ផ្តើមធ្វើវាទៅហើយ ។ អ្នកអាចរីករាយជា មុន សម្លឹងទៅខាងមុខ ដើម្បីរងចាំការល្អមកដល់ ។

មានមនុស្សជាច្រើនរស់នៅដូចអ្វីដែលគេជឿ ពួកគេមិនអាចរីករាយក្នុងជីវិតរបស់ គេឡើយដរាបណាពួកគេនៅមានបញ្ហាជាច្រើន ប៉ុន្តែការនោះគឺជាការគិតខុស ។ ចូរកុំ កុំរស់នៅអាស្រ័យលើកំហុស ឬ សោកស្តាយរឿងអតីតកាលរបស់អ្នកឡើយ ។ សូម បន្តគិតអំពីអនាគតថ្មីដ៏ល្អបំផុតដែលអ្នកមានតាមរយៈព្រះយេស៊ូគ្រិស្តវិញ ។ អ្នកអាច រីករាយនឹងអ្វីៗដែលអ្នកសំរេចចិត្តដើម្បីរីករាយ ។ អ្នកក៏អាចរីករាយក្នុងការអង្គុយ ពេលស្ទះចរាចរបាន បើសិនអ្នកប្តេជ្ញាធ្វើ ។ សូមចងចាំថា ខ្ញុំកំពុងបង្រៀនអ្នកពីររបៀប រស់នៅបែបថ្មី និងអាកប្បកិរិយាអ្នកចំពោះជីវិតដែលជាផ្នែកមួយដ៏ធំនៃភាពរីករាយ ។

ជាទីបញ្ចប់ខ្ញុំបានរៀនអំពីភាពរីករាយគ្រប់ទីកន្លែងដែលខ្ញុំទៅ ខណៈខ្ញុំកំពុងធ្វើដំ ណើរទៅកន្លែងណាក្តី ហើយខ្ញុំសូមជំរុញអ្នកយ៉ាងខ្លាំងឱ្យធ្វើការដូចនេះដែរ ។ មានកិច្ច ការជាច្រើនដែលព្រះត្រូវធ្វើនៅក្នុងជីវិតរបស់អ្នក ហើយទ្រង់មិនចង់ឱ្យអ្នកមានទុក្ខ លំបាកនៅពេលទ្រង់កំពុងធ្វើការនោះឡើយ ។ ចូរធ្វើដូចជាទារកដែលរីកលូតលាស់ទៅ ជាមនុស្សពេញវ័យ ។ គ្រិស្តបរិស័ទក៏ត្រូវតែលូតលាស់ដែរ ។ នេះជាដំណើរការដែល ជាញឹកញាប់ត្រូវប្រើរយៈពេលយូរជាងដែលយើងចង់បាន ប៉ុន្តែគ្មានចំណុចណាមួយ ដែលថាមិនមានអំណរក្នុងការធ្វើដំណើរនោះទេ ។

## របៀបរស់នៅបែបថ្មី

ព្រះជាម្ចាស់មិនសង្ឃឹមថា ថ្ងៃនេះអ្នកធ្វើបានល្អឥតខ្ចោះនោះទេ។ ជាការពិតព្រះបានជ្រាបជាស្រេចថា អ្នកនឹងមិនអាចធ្វើបានល្អឥតខ្ចោះនោះទេ ដរាបណាអ្នកនៅរស់នៅលើផែនដីនេះនៅឡើយ ។ តែទោះបីជាយ៉ាងណាក៏ដោយព្រះនៅតែមានសង្ឃឹមលើយើងម្នាក់ៗនៅតែបន្តធ្វើទៀត ។ យើងគួរតែក្រោកឡើងរាល់ថ្ងៃ ហើយបំរើព្រះអង្គដោយស្មោះត្រង់អស់ពីចិត្តរបស់យើង ។ យើងគួរតែថ្វាយរាល់កំហុសរបស់យើង ហើយសុំឱ្យព្រះអង្គអត់ទោសរាល់អំពើបាបរបស់យើងដោយដួងចិត្តផ្លាស់ប្រែពីកំហុសនោះ ។ ប្រសិនបើយើងធ្វើការនេះមែន នោះព្រះនឹងអត់ទោសឱ្យ ព្រះអង្គទ្រង់នឹងធ្វើការចំណែកព្រះអង្គ ។ ព្រះទ្រង់នឹងនៅតែធ្វើការជាមួយយើង តាមរយៈព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ។ ព្រះទ្រង់នឹងបង្រៀនយើង ផ្លាស់ប្តូរយើង ហើយប្រើប្រាស់យើង ។ អ្នកបានឈានចូលទៅក្នុងរបៀបរស់នៅថ្មី ហើយខ្ញុំជឿថាអ្នកនឹងមិនសោកស្តាយឡើយ ។ ចូររីករាយនឹងព្រះជាម្ចាស់, រីករាយនឹងខ្លួនឯង ហើយរីករាយនឹងជីវិតដែលព្រះយេស៊ូបានសុគតសំរាប់អ្នក!

# ការអធិស្ឋានដើម្បីបានសង្គ្រោះ

"ព្រះអម្ចាស់ស្រឡាញ់អ្នក ហើយចង់មានទំនាក់ទំនងដោយផ្ទាល់ជាមួយអ្នក។ បើសិនជា អ្នកមិនទាន់ទទួលព្រះយេស៊ូគ្រិស្តជាព្រះអង្គសង្គ្រោះរបស់អ្នកនៅឡើយ នោះអ្នកអាចទទួលឥឡូវនេះបាន។ សូមបើកចំហដួងចិត្តរបស់អ្នកចំពោះព្រះអង្គ និង អធិស្ឋានដូចខាងក្រោម:

"ឱព្រះវរបិតាអើយទូលបង្គំដឹងថាទូលបង្គំមានបាបទាស់នឹងព្រះអង្គ។ សូមអត់ទោសបាបដល់ទូលបង្គំ សូមលាងសំអាតទូលបង្គំ។ ទូលបង្គំសន្យាថាទុកចិត្តព្រះយេស៊ូជាព្រះរាជបុត្រារបស់ព្រះអង្គ។ ទូលបង្គំជឿថាព្រះយេស៊ូសុគតដោយព្រោះទូលបង្គំ ព្រះអង្គទ្រង់បានយកបាបរបស់ទូលបង្គំដាក់លើអង្គទ្រង់នៅពេលទ្រង់សុគតនៅលើឈើឆ្កាង។ ទូលបង្គំជឿថាព្រះអង្គបានមានព្រះជន្មរស់ពីសុគតឡើងវិញ។ ទូលបង្គំសូមថ្វាយជីវិតដាច់ដល់ព្រះអង្គឥឡូវនេះ។ ទូលបង្គំ សូមអរព្រះគុណដល់ព្រះវរបិតាដែលបានប្រទានការអត់ទោសនិងជីវិតអស់កល្ប៍។សូមព្រះអង្គជួយដល់ទូលបង្គំដើម្បីរស់នៅសំរាប់ព្រះអង្គ។ ទូលបង្គំអធិស្ឋាន ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត! អាម៉ែន។"

នៅពេលអ្នកអធិស្ឋានចេញពីដួងចិត្តរបស់អ្នក ព្រះជាម្ចាស់បានទទួលយកអ្នក សំអាតអ្នក និងរំដោះអ្នកឲ្យមានសេរីភាពពីចំណងនៃសេចក្តីស្លាប់ខាងវិញ្ញាណ។ សូមចំណាយពេលអាននិងសិក្សាព្រះបន្ទូលទាំងនេះ ហើយទូលសូមព្រះជាម្ចាស់ដើម្បីនិយាយទៅកាន់អ្នក ដូចជាអ្នកដើរជាមួយទ្រង់តាមរយៈដំណើរនេះនៅក្នុងជីវិតថ្មីរ។

| | |
|---|---|
| យ៉ូហាន ៣:១៦ | ១កូរិនថូស ១៥:៣-៤ |
| ១ យ៉ូហាន ១:៩ | ១ យ៉ូហាន ៤:១៤-១៥ |
| អេភេសូរ ១:៤ | អេភេសូរ ២:៨-៩ |
| ១ យ៉ូហាន ៥:១ | ១ យ៉ូហាន ៥:១២-១៣ |

សូមអធិស្ឋាននិងទូលសុំព្រះឲ្យជួយអ្នករកបានព្រះវិហារ ដែលមានជំនឿតាមព្រះគម្ពីរ ដែលអាចជួយអ្នកឲ្យរីកចំរើននៅក្នុងទំនាក់ទំនងរបស់អ្នកជាមួយព្រះគ្រិស្ត។ ព្រះជាម្ចាស់គង់ជាមួយអ្នកជានិច្ច។ ព្រះទ្រង់នឹងដឹកនាំអ្នកពីមួយថ្ងៃទៅមួយថ្ងៃ ហើយនឹងបង្ហាញអ្នកពីរបៀបរស់នៅជីវិតពេញបរិបូរដែលព្រះអង្គមានសំរាប់អ្នក!

# ប្រភពអនុសាសន៍

ខ្ញុំមានធនធានជាច្រើនដែលអាចប្រើប្រាស់បានជាប្រយោជន៍ ដែលនឹងអាចជួយអ្នកឱ្យរៀននិងលូតលាស់ក្នុងជីវិតមួយថ្មីរបស់អ្នក។ អ្នកអាចស្នើសុំសៀវភៅកត្តឡុក ហើយពេលមួយនឹងផ្ញើឱ្យអ្នកដោយមិនគិតថ្លៃ។ ខ្ញុំក៏សូមផ្តាំថា អ្នកអាចស្នើសុំទស្សនាវដ្ដីប្រចាំខែរបស់យើង ដែលនឹងផ្ញើទៅអ្នកដោយមិនគិតថ្លៃសំរាប់ពីរបីខែ។

ខ្ញុំសូមណែនាំពីសៀវភៅរបស់ខ្ញុំដូចជា *សមរភូមិនៃគំនិត* និង *សៀវភៅរបៀបយកជ័យជំនះលើការធ្វើជាខ្លួនឯង*។ *ខ្ញុំណែនាំទាំងពាក្យ និង ឈ្មោះ* សៀវភៅមួយឈ្មោះថា *ព្រះលោហិត* ដែលជាសៀវភៅអាចជួយអ្នកឱ្យចាក់ គ្រឹះយ៉ាងរឹងមាំក្នុងជីវិតរបស់អ្នកចំពោះអ្វីៗដែលព្រះយេស៊ូបានធ្វើសំរាប់អ្នកនៅលើឈើឆ្កាង ហើយនិងអំណាចដែលអាចប្រើប្រាស់បានឱ្យទៅជាប្រយោជន៍សំរាប់អ្នកឥឡូវនេះ ដូចជាអ្នកជឿ ដល់ទ្រង់ដែរ។ *Pressing in and Pressing on* គឺជាប្រភេទការសែត និង ស៊ីឌីដែលមានការបង្រៀនដ៏ល្អអាចប្រើប្រាស់បាន ហើយនិងសៀវភៅ*The Mouth* (*មាត់*) ក៏ជាប្រភេទសៀវភៅដែលអាចជួយអ្នករៀន អំពីអំណាចនៃពាក្យសម្ដីរបស់អ្នក។

ប្រសិនបើយើងអាចជួយអ្នកបាននូវអ្វីផ្សេងទៀតសូមទូរស័ព្ទមកកាន់ការិយាល័យរបស់យើងខ្ញុំហើយត្រូវចងចាំថាព្រះអង្គស្រឡាញ់អ្នកហើយយើងក៏ស្រឡាញ់អ្នកដែរ!

# សៀវភៅផ្សេងទៀតដែលនិពន្ធដោយអ្នកស្រី ចយស៏ ម៉ៃយ័រ

The Everyday Life Bible (hardcover or bonded Leather)

The Confident Woman

Look Great Fell Great

Battlefield of the Mind*

Battlefield of the Mind Devotional

Approval Addition

Ending Your Day

In Pursuit of Place

The Secret Power of Speaking God's Word

Seven Things That Steal Your Joy

Starting Your Day Right

Beauty for Ashes (revised edition)

How to Hear from God*

Knowing God Intimately

The Power of Simple Prayer

The Battle belongs to the Lord

The Secrets to Exceptional Living

Eight Ways to keep the Devil Under Your Feet

Teenagers Are People Too!

Filled with the Spirit

Celebration of Simplicity

The Joy of Believing Prayer

Never Lose Heart

Being the person God Made You to Be

A Leader in the Making

“ Good Morning, This Is God! ” (gift books)

Jesus- Name Above All Names

Making Marriage Work

(Previously published as Help Me-I’m Married)

Reduce me to Love

Be Healed in Jesus’s Name

How to Succeed at Being Yourself

Weary Warriors, Fainting Saints

Be Anxious for Nothing*

Straight Talk Omnibus

Don’t Dread

Managing Your Emotions

Healing the Brokenhearted

Me and My Big Mouth!*

Prepare to Proper

Do It Afraid!

Expect a Move of God in Life… Suddenly!

Enjoying Where Your Are on the Way

To Where You Are Going

The Most Important Decision You Will Ever Make

When, God, When?

Why, God, Why?

The Word, the Name, the Blood

Tell Them I Love Them

Peace

If Not for the Grace of God*

## សៀវភៅសរសេរដោយលោកដេវ

Life Lines

# អំពីអ្នកនិពន្ធ

អ្នកស្រី ចយស៍ ម៉ៃយ័ គឺជាគ្រូបង្រៀនព្រះបន្ទូលអនុវត្តន៏ជាក់ស្តែងម្នាក់ដែលនាំមុខគេនៅលើពិភពលោកនេះ។ អ្នកស្រី ជាអ្នកនិពន្ធលក់ដាច់ជាងគេបង្អស់ លេខ១ញ៉ូវយ៉កថែមស៏ *New York Times best-selling* អ្នកស្រីបានសរសេរសៀវភៅខាងព្រលឹងវិញ្ញាណជាង៧0ក្បាល ដោយរួមបញ្ចូលទាំងសៀវភៅ *Confident Woman, Look Great, Feel Great, Battle Field of the Mind* និងសៀវភៅផ្សេងៗទៀតជាច្រើន។ អ្នកស្រីក៏បានបញ្ចេញ កាសែតស្តាប់ បង្រៀនមេរៀនរាប់ពាន់កាសែត និង បណ្តាល័យកាសែតវីដេអូ ផងដែរ។ កម្មវិធី ជីវិតរីករាយប្រចាំថ្ងៃត្រូវបានចាក់ផ្សាយតាមវិទ្យុ និង ទូរទស្សន៍ នៅជុំវិញពិភពលោក ហើយអ្នកស្រី ធ្វើដំណើរយ៉ាងសកម្មក្នុងការហ្វឹកហ្វឺនតាមរយៈការធ្វើ សិក្ខាសាលា ឬ សន្និបាតធំៗ។ អ្នកស្រី ចយស៏ ជាភរិយា លោកគ្រូគង្វាល ដេវ និង ជាគ្រួសារដែលមានកូន បួននាក់ និងរស់នៅសហរដ្ឋអាមេរិក រដ្ឋ មីស៊ូរី St. Louis, Missouri.